# ការសំភាសន៍ជាលើកទី២របស់អ៊ំស្រី ជុក ហ៊ាន

កៈ អ្នកដែលសំភាសន៍ ញៀម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ជុក ហ៊ាន

## ការសង្ខេបជាលើកទី២របស់អ៊ំស្រី ជុក ហ៊ាន

អ៊ំស្រីជុក ហ៊ាន នៅមិនបានរៀនដល់ថ្នាក់ទីប៉ុន្មានទីប៉ុន្មានទេ តែគាត់បានរៀនអក្ខរកម្ម ហើយគាត់ចង់រៀនណាស់ តែដោយសារគាត់រស់នៅមិនមែនជាមួយម្ដាយឪពុកបង្កើតទើបធ្វើអោយគាត់មិនបានរៀនស្រួលប្រួល។ អ៊ំស្រីមានស្វាមីលើកទីមួយគឺនៅត្រូវបានប៉ុលពតរៀបអោយតែក្រោយមកគេបានបាញ់ប្ដីគាត់ស្លាប់ ហើយគាត់មានកូនម្នាក់ហើយបន្ទាប់ពីពេលបែកពីសង្គ្រាមប៉ុលពតគាត់បានហើយគាត់ទៅរស់នៅជំរុំគាត់ក៏បានជួបស្វាមីក្រោយហើយរៀបការនៅទីនោះ ហើយដល់ពេលបានកូន៣ ៩ប្ដីគាត់បានទៅមានស្រីហើយពួកគាត់បានលែងលះគ្នា ហើយគាត់រស់នៅជាមួយកូន។ អ៊ំនៅក្នុងរបបសង្គ្រាមប៉ុលពតគាត់ជាអ្នកដាំបាយអោយគេហើយពេលខ្លះក៏គាត់ជួបទុក្ខលំបាកដែរព្រោះសង្គ្រាមនោះបានធ្វើអោយប្រជាជនវេទនា។ សព្វថ្ងៃអ៊ំប្រកបមុខរបរដើររើសអេតចាយដើម្បីចិញ្ចឹមខ្លួនហើយនឹងចៅ។ អ៊ំស្រីជាមនុស្សម្នាក់ដែលល្អហើយពុះពារខ្លាំងនៅក្នុងជីវិត។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ំស្រីដែលអោយសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ំនាងខ្ញុំឈ្មោះញៀម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ំនៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍គឺនៅក្នុងថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិព្រែកថ្លឹង!!

ខៈ សង្កាត់ជើងឯក។

កៈ សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញប្រទេសកម្ពុជា។ អញ្ចឹងពេលមុនញ៉ុមបានសំភាសន៍អ៊ំម្ដងហើយហើយអ៊ីចឹងចង់អោយអ៊ំនិយាយខ្លះៗទៀតអំពី

សាច់រឿងដែលអ៊ំមិនទាន់បាននិយាយអ៊ីចឹងអ៊ំចង់ដឹងពីនេះហា៎ ពីការសិក្សារបស់អ៊ំ អ៊ំរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ អត់!!

ក៖ អូ ហ្នឹងហើយ!!

ខ៖ អក្ខរកម្មហ្នឹង!!

ក៖ ម៉េចដែរអ៊ំការរៀនអក្ខរកម្មហ្នឹង?

ខ៖ រៀនហ្នឹងគ្រាន់តែថាអោយយើងចេះមើលឈ្មោះមើលអីប៉ុណ្ណឹង សរសេរ សរសេរមិនត្រូវជ្រុងផងហ្នឹង។

ក៖ ឥឡូវចេះអានទេ?

ខ៖ ញ៉ុមមើល ញ៉ុមមើលបានតែម៉ាត្រឹមឈ្មោះញ៉ុមថាលេខអីបន្តិចបន្តួចទេ។

ក៖ តែប៉ុណ្ណឹងទេហេ?

ខ៖ ហ្នឹងហើយ អត់ចេះសោះ ១ខែកូនឯង។

ក៖ រៀនបានតែមួយខែទេអញ្ចឹង?

ខ៖ រៀនបានតែមួយខែទេ ។

ក៖ ម៉េចតិចម្លេះ?

ខ៖ មួយខែដឹងម៉េចទេកុំអីគ្រូគេនៅរៀនទៀតហើយ ម្នាក់នោះប្តីដល់ទៅគ្រូបង្រៀនតែអត់មានចេះអក្សរអីមួយតួ បងថ្លៃជីដូនមួយ ដល់ឈ្មោះគ្រូរ៉ែនហ្នឹងគាត់នៅព្រះវិហារហ្នុំ ដល់ពេលរៀនយប់ឡើងក្តារខៀនមួយក្រោមដើមក្រសាំងដើមត្នោតហ្នឹងផ្ទះសព្វចង្កៀងម៉ាំង សុង ប្រេងកាតមួយប៉ោងហ្នឹងសហការណ៍គ្នា១០០ ១០០ទិញទៅ។

ក៖ ចា៎!!

ខ៖ ដល់ពេលអស់យើងអង្កៀសគ្នាទៀតទៅ គេបង្រៀនគេមានយកលុយយើងណា។

ក៖ អ៊ីចឹងចង្កៀងហ្នឹងសុទ្ធតែទិញដាក់ប៉ោង?

ខ៖ ប៉ោងផ្លិតហា៎!!

ក៖ ចា៎!!

ខ៖ អាប្រេងកាតប្រេងកាតបួនជ្រុងអាប្រេងកាត់ដាក់ប៉ោតហា៎!!

ក៖ ចា៎!!

ខ៖
ហ្នឹងហើយហើយដល់ពេលនេះទៅគេអុជចង្កៀងម៉ាំងសុងទេតាមភូមិអញ្ចឹងអ្នកចាស់ៗអត់ចេះអក្សរយកមករៀនទាំងអស់។

ក៖ ចា៎!!

ខ៖
ដាក់គ្រែជាប់គ្នាដល់តែពេលបងញ៉ុមជីដូនមួយនោះគាត់ប្តីគាត់គ្រូបង្រៀនស្មានតែគាត់ចេះអក្សរដល់តែគេប្រមូលលុយអោយគេទន្ទេញស្រះ អ ស្រះ អា ទន្ទេញវាមិនត្រូវជួរ ហ៊ីរំពាត់ផ្តៅវ៉ៃរហូតហ៊ុអង្កែលហ្នឹង!! ហើយប៉ុន្មាននាក់ទៀតបងជីដូនមួយញ៉ុមយាយស៊ីមតែប្រពន្ធតាលេងភ្លេងហា៎!!!ហើយបានមកបងញ៉ុម គាត់បានកូនស្រីមួយឈ្មោះមី លឹម ហេង។

ក៖ ចា៎!!

ខ៖ ដល់ពេលនេះទៅខឹងប្តីវ៉ៃ អាត្រូវគ្រាប់វ៉ៃអញឈឺៗ គ្រូបង្រៀនអីអញមិនរៀនទេ អាណាគេយកអញទៅបាញ់ចោលទាស់គ្នាចង់លែងលះគ្នាអារឿងរៀនហ្នឹងហ៎!!ដល់ពេលនេះទៅវាឈប់រៀនវាអស់សិស្សរៀននោះ!!

ក៖ ចា៎!!

ខ៖ គ្រូហ្នឹងគេឈប់បង្រៀនទៅ។

ក៖ ហ្ន៎!!

ខ៖ ហើយញ៉ុមរៀនបានតែមួយខែគត់
តិចទៅបងហ្នឹងថាហោមិនដឹងទៅរៀនធ្វើអីទេមើលប្អូនហិ គាត់ដើរ!!

ក៖ ទៅលេងបៀរបាត់ទៅ!!

ខ៖ ពេលយប់គាត់ទៅ អាប៉ោងក៏គាត់ចេះចាក់ កន្ទុយលេខក៏គាត់ចេះលេង។

ក៖ សម័យហ្នឹងគេមានកន្ទុយលេខដែរអ៊ំហោ?

ខ៖ ហោ មេគេនៅវត្តព្រែកសំរោងយើងនេះ។

ក៖ ហ្ហ៎!!

ខ៖ លេងណាស់!!អារម៉ក់ជើងហ្នឹងចេះតែទៅហើយ
អាពោះប៉ុនកញ្ជើរពោះឡើងគ្រប់ខែឥឡូវហើយហ្នឹងហា៎!!ទៅ។

ក៖ គាត់ទៅទៀត?

ខ៖ ហ្ហ៎បងញ៉ុមគាត់មកបើឈ្នះអត់អីទេ
តែបើចាញ់វិញអ្នកក្នុងផ្ទះហ្នឹងមុខតែខ្វាត់ខ្វាយហើយខុសរហូត!!

ក៖ ចា៎!!

ខ៖ អត់មានត្រូវទេ !!

ក៖ ហើយនៅប៉ុន្មាននាក់ពេលហ្នឹងអ៊ំ?

ខ៖ មានណាមានតែញ៉ុមហ្នឹង មានតែកូនគាត់ញ៉ុម។ក៖ ហ្ហ៎!!ខ៖ កូនគាត់២។

ក៖ ចា៎ហើយអ៊ំមួយអញ្ជឹងទៅ?

ខ៖ ចា៎ហើយពីរនាក់ប្ដីប្រពន្ធគាត់ហ្នឹង។

ក៖ ចា៎!!

ខ៖
ប្រពន្ធរែកទឹកការធ្វើការអីគាត់ដូចថាការនៅឯណាគេជួលរែកទឹកហាំរែកពីក្នុងស្ទឹងយកដាក់ក្នុងពាងគេហាំ!!

ក៖ ចំ!!ប្តីឬក៏ប្រពន្ធ?

ខ៖ ប្តីហាំ!!

ក៖ ប្តីទេហេ!!

ខ៖ ហើយប្រពន្ធអញ្ចឹង។

ក៖ លេងបៀរ!!

ខ៖ ហើយកេរ្តិ៍គាត់ច្រើនណាស់នេះស្រែអោយញ៉ុមដើរបង្ហាញទៅ ឥឡូវអោយគេហើយ។

ក៖ អាហ្នឹងដោយសារចរិកមិនកើតអំណោះ?

ខ៖ ហ្នឹងហើយ។

ក៖ ចិត្តគំនិតមិនកើត!!

ខ៖ អស់គោ អស់អី អាគោចែកឯងយកទៅលក់ញ៉ុមខឹងណាស់
ញ៉ុមលួចរត់ទៅភ្នំពេញទៅញ៉ុមស្គាល់ហើយ។

ក៖ ហើយគាត់អត់ទៅតាណាអំហេ?

ខ៖ ទៅរកឃើញហេ គាត់អត់ដែលឃើញអត់ដែល!

ក៖ អត់ដែលស្គាល់ភ្នំពេញផងហេ?

ខ៖ ញ៉ុមអត់ដែលស្គាល់ភ្នំពេញដែរប៉ុន្តែម្តាយធំញ៉ុមឈ្មោះធំណឹម ធំណឹមជូនទៅ ទៅទៅ
ទៅមានអីគេអោយញ៉ុមដាំបាយធ្វើម្ហូបដាក់បាតលោករហូត។

ក៖ ហ៊ីៗ!!

ខ៖ ញ៉ុមព្រលឹមឡើងដឹងតែដាក់ដាំបាយដាក់បាតលោកម៉ោង៦មួយសារម៉ោង៩មួយសារ។ក៖ ចាំ!!ខ៖ មួយថ្ងៃពីរពេល។

ក៖ គាត់អ្នកមានខ្លាំងអឹហេ ចិត្តល្អខ្លាំងអឹហេ?

ខ៖  កូនគេមេគយហាំ កូនប្រសារគេមេគយ ហើយលោកថ្ងៃសីលលោកនិមន្តមកផ្ទះយើងហាំ!!ក៖ ហ៊ឺៗ!!

ខ៖ យើងក្រាលកន្ទេលដើរកាច់ផ្កាគ្រប់ គ្រប់ទាំងអស់ ផ្កាគ្រប់ប្រភេទ។

ក៖ ចាំ!!

ខ៖ ញ៉ុមយកមកជ្រៀកអាធាងដូងយើងហ្នឹងដាក់មានតាំងពីចំប៉ា មានតាំងពីផ្កាកុលាបមានម្លិះមានផ្កាអីច្រើនណាស់កាលហ្នឹងញ៉ុមនៅនេះដែរញ៉ុមចាំច្បាស់ណាស់ ដល់នេះញ៉ុមក្រាលកន្ទេលដាក់អីលោកនិមន្តមកមួយអង្គ។

ក៖ ចាំ!!

ខ៖ និមន្តមកធ្វើសីលហើយ!!ហើយយាយនោះថាហ្អែងកុំ កុំទទួលសីល៨ហាំហ្អែងនៅញុំាបាយពេលល្ងាចកុំទទួល ទទួលត្រឹម៥បានហើយ ញ៉ុមធ្វើបានមួយឆ្នាំហាំ!!

ក៖ ចាំ!!

ខ៖ បានញ៉ុមទៅអាពតអត់ អត់អីហាំ!!

ក៖ ចាំ!!

ខ៖ ញ៉ុមទៅប៉ុល ពតគេអានិតស្រលាញ់ អ្នករំដោះចាស់ប្រធានពេទ្យទៀតណាស់!!

ក៖ ចាំ!!

ខ៖ អានិតញ៉ុមឈឺញ៉ុមសុំចេញមកវិញមក គាត់ថាកុំអាលទៅ ទៅក្នុងកងគេប្រើទៀតហើយ នៅតិចទៀតទៅ សុទ្ធអញ្ជឹងហាំ!!

ក៖ ចាំ!!

ខ៖ ហ្នឹងហើយអ៊ីចឹងបានថាប្រវត្តិនៅអាពតដូចម្យ៉ាងញ៉ុមមានសំណាងវិញ មានសំណាងដូចថាគេអានិតគេស្រលាញ់ញ៉ុមហាំ!!

ក៖ ចាំ!!អញ្ចឹងហេងហើយអំណេះ?

ខ៖
ចាំហ្នឹងហើយ!!បានញ៉ុមចេះតែថាហ៊ីឃើញគេបណ្តើរទាំងខ្សែៗទាំងខ្សែហ៊ីថ្ងៃនេះគេថ្ងៃក្រោយ ឯងហើយមិនដឹងថាបានទៅស្រុកវិញហីអត់ទេ?

ក៖ ចាំ!!

ខ៖ ចេះតែអញ្ចឹងហាំ!!

ក៖ ឥឡូវអ៊ំ អ៊ិចឹងឈប់សិនអ៊ំមុនហ្នឹងចូលអាហ្នឹង
អ៊ំមុនពេលនឹងចូលជំនាន់ប៉ុលពតអ៊ំនិយាយអាពីរៀនសិនអ៊ំពេលនៅរៀន
ទោះថាមិនបានរៀនជ្រៅក៏ដោយ
ទោះថារៀនអក្ខរកម្មក៏ដោយតែនៅពីក្មេងអីធ្លាប់មានក្តីស្រម៉ៃអីអត់អ៊ំ?

ខ៖ អត់ៗ

ក៖ អត់មានដែលថាធំឡើងប្រាថ្នាធ្វើគ្រូបង្រៀនអីអញ្ចេះៗហាំ?

ខ៖
ហ៊ីញ៉ុមនឹកឃើញក្នុងចិត្តញ៉ុមថាអញ្ចេកបើបងជីដូនមួយញ៉ុមហ្នឹងអោយញ៉ុមទៅរៀនហាំ!!ក៖ ហ៊ីៗ!!

ខ៖ ញ៉ុមហោចណាស់ក៏ញ៉ុមបានធ្វើត្រឹមគ្រូបង្រៀនដែរ!!ខ្ញុំចង់ណាស់!!

ក៖ ចង់ធ្វើគ្រូបង្រៀនហេ?

ខ៖ ចង់ណាស់ ញ៉ូមរៀនហាំលោកគ្រូសរសើរញ៉ុមម៉ងហាំ!!

ក៖ ចាំ!!

ខ៖ ទោះញ៉ុមខានមួយយប់ទៅហាំអក្សរញ៉ុមអត់ដែលអានហាំញ៉ុមឡើងអាន!!

ក៖ បានម៉ង!!

ខ៖ អាន បណ្តោយអញ្ចឹងហើយគេអោយយើងអានបញ្ច្រាស់!!

ក៖ ចាំ!!

ខ៖ ដូចជា

ក ខ អ៊ីចឹងហិ ចប់ហើយគេអោយរាប់បញ្ច្រាស់ បើនាក់រាប់បញ្ច្រាស់អត់ចាំគឺចាំមាត់ទេ!!

ក៖ ចាំហ្នឹងហើយ!!

ខ៖ ចាញ៉ុមគ្រាន់បើញ៉ុមដឹងថាខ្លួនញ៉ុមពូកែ!!

ក៖ ភាគច្រើនអក្សរខ្មែររាប់ចាំមាត់ ក ខ គ ឃ ង!!

ខ៖ ហ្នឹងហើយ!!

ក៖ បើសិនជារាប់បញ្ច្រាស់មកវិញបានដឹង បានដឹងថាអ្នកណាចេះឬក៏អត់។

ខ៖ បានដឹងថាអ្នកណាចេះ!!

ក៖ ចាំហ្នឹងហើយ!!

ខ៖ មិនមែនទេ ហើយញ៉ុមសួរថៅញ៉ុមម៉ាប់កូនឯងទៅរៀនគ្រូដែលអោយរៀនរាប់បញ្ច្រាស់
បណ្តោយទេ? វាថាអត់ផង!!ក្មេងៗវាចាំ ហើយញ៉ុមអត់ចាំមាត់ទេ!!ញ៉ុមចាំច្បាស់
មកយប់ហាំមុនហ្នឹងអោយវាចុចទូរទស្សន៍មើលកូនណាស់
បិតអាហ្នឹងចោលសិនយកសៀវភៅអាកូនឯងបានរៀនថ្ងៃហ្នឹងហាំ!!

ក៖ អាអូនឥឡូវៗហ្នឹងហោ?

ខ៖ ចាំ!!កូនឯងអានអោយចប់ហើយអោយយាយស្តាប់ចាំមើលអីមើលទៅ!!!

ក៖ ហ្វាំ!!

ខ៖ ប្រាប់វា។

ក៖ ហ្ន៎!!ចា៎!!រៀនអាអូនថៅហ្នឹង!!

ខ៖ អូនឯងហា៎យើងក្រគេមើលងាយណាស់ !!!

ក៖ ហ៊ីៗ!!

ខ៖ ហ្អែងដឹងទេ មីងហ្អែងនេះប្រមាណម៉ែឪហ្អែងម៉េចខ្លះ។

ក៖ ចា៎!

ខ៖
ហ្អែងអោយមានការឈឺចាប់ហា៎!!អញកូនឯងចេះទៅមិនដឹងឡើងជាស្អីក៏មិនដឹងទេនិស្ស័យរបស់កូនឯងអញមើលមិនឃើញទេណាស់!!

ក៖ ហ៊ីៗ!!

ខ៖ យាយក៏កូនឯងអត់បានចិញ្ចឹមទេ
យាយធ្វើបុណ្យនេះយាយមិនបានធ្វើបុណ្យអីធំដុំទេយាយខំតែរកលុយហ្នឹងហិដើម្បីអោយកូណាឯងចេះអក្សរជាតិក្រោយយាយចេះហើយ។

ក៖ ចា៎!!

ខ៖ យាយប្រាថ្នាប៉ុណ្ណឹងទេ!!។

ក៖ ហ្នឹងហើយអ៊ំសុខចិត្តទៅរើស!!

ខ៖
ហ្នឹងហើយយាយអត់ចង់បានកំលាំងថាហ៊ីអត់ចង់បានថាហ៊ីពេលហ្អែងរៀនចេះដឹងហ្អែងរៀនធ្វើការយកលុយអោយចិញ្ចឹមយាយយាយអត់ចង់បាន។

ក៖ ហ៊ីៗ!!

ខ៖ កូនឯងមានអនាគតចិញ្ចឹមឪពុកម្តាយថៅឯងហា៎។

ក៖ ចាំ!!

ខ៖ យាយប្រាថ្នាអោយជាតិក្រោយទៅយាយចេះអក្សរ។

ក៖ ហ៊ឺៗ!!

ខ៖ អត់បាច់ធ្វើបុណ្យលោកសង្ឃណាទេនិយាយត្រង់ យាយធ្វើបុណ្យថៅឯង!!

ក៖ ចាំ!

ខ៖ ញ៉ុមប្រាប់ថៅញ៉ូមអញ្ចឹង!!

ក៖ ហ្នឹងហើយ!!អ៊ំបានអោយជួយគាត់ អ៊ំខំដើរពីណាពីណីមក!!

ខ៖  ហ្នឹងហើយ ចេះទៅហាំនេះហិ អាអំពើចេះរបស់ថៅឯងហ្នឹងហាំ
ក៏ផ្តល់ពីយាយអោយថៅឯងចេះ។

ក៖ ហ៊ឺៗ!!

ខ៖ អញ្ចឹងជាពន្លឺជាចង្កៀង ជាភ្លើងមួយបំភ្លឺអោយថៅឯង
ជាតិអនាគតទៅថៅឯងចេះដូចថៅឯងហើយ!!

ក៖ ចាំ!

ខ៖ មិននេះទេ យាយរៀនហើយក៏រៀនពូកែទៀត!!

ក៖ ហ៊ឺៗ!!

ខ៖ ជាតិនេះធ្វើម៉េចបើយាយកសាងពីអតីតជាតិមិនល្អទៅនៅ
យាយចង់ចេះណាស់ម៉ាប់ហាំបើអញរៀនហាំហោចណាស់ក៏អញត្រឹមគ្រូបង្រៀនដែរ!!

ក៖  ចាំមែនហ្នឹងអ៊ំ អ៊ំបើនៅរៀនអ៊ំពូកែខ្លាំងម៉ងនេះ!!!!

ខ៖ ញ៉ុមចង់ ញ៉ុមចង់តែចេះ មានអារម្មណ៍មួយថាបើអញបានចេះអក្សរអញអត់ពិបាកទេ ខ្ញុំហាំពីមុនគ្រាន់មានទឹកដីនេះអាផ្ទះនេះជាប់ញ៉ុមនេះផ្ទះញ៉ុមហើយតែមកពីញ៉ុមអត់ពេកញ៉ុមលក់ទៅ កាលញ៉ុមនៅតែម្នាក់ឯងញ៉ុមឈឺហ្មំ!!

ក៖ ចាំ!!ខ៖ លក់ទៅ កាលហ្នឹងលក់អាដីគេ គេលក់អាដីរួមទេគេអោយវាស់ វាស់អាដីរួមនេះញ៉ូមវាស់បាន មុនដំបូងញ៉ុមចែកអោយកូនបានតែ៩ម៉ែត្រទេណាស់។

ក៖ ហ៊ីៗ!!!

ខ៖
ដីហ្នឹងហាំដល់ញ៉ុមអត់ពេកញ៉ូមលក់កូនញ៉ុមប្រាប់ថាម៉ែឯងសួរម៉ែក្មេកហ្អែងមើលទៅទិញដីនេះទេ អញ
អញលក់ហើយអត់មានលុយមើលខ្លួនទេហើយណាមួយអញអត់អីទិញស៊ីទៀតអញធ្វើការអីកើត ញ៉ុមលក់ផ្ទះហ្នឹងទៅគេនៅលើផ្ទះនោះគាត់នៅផ្សារដឹមុិចគាត់អោយញ៉ុមនៅ
នៅគាត់សួរញ៉ុមញ៉ុមទៅប្រជុំភូមិហ្មំ!!ហ៊ីទៅហើយបងឯងនៅមើលបងឯងយកប្រាក់ខែអត់?ញ៉ុមថាហ៊ីមីចែអើយញ៉ុមយកប្រាប់ខែមីចែឯងញ៉ុមក៏ចិញ្ចឹមកូនអត់គ្រប់ដែរ
ចុះញ៉ុមនៅញ៉ុមនៅមានកំលាំងជួលស្ទូងដកអោយកេបាន។

ក៖ ហ៊ីៗ!!

ខ៖
តែចែឯងកុំភ័យណាស់ត្បិតតែញ៉ុមអត់យកប្រាក់ខែមីចែឯងតែដីញ៉ុមធ្វើមួយវាលមួយសំមួយស្អាតម៉ង!!

ក៖ ហ៊ីៗ!!

ខ៖ មួយណាមក មីអូនឯងស៊ីប្រាក់ខែគេអត់?នោះតាគឹមហ្មំ!!ញ៉ុមថាញ៉ុមអត់ផង រួចអត់ស៊ីប្រាក់ខែរួចក៏ដីស្អាតៗផ្លឹងៗម្ល៉េះ? អូនមើលពីរបងកើតធ្លាយទៅលិច លវឹងក្រោមដើមស្វាយត្រជាក់ល្ហឹមទៅណាស់!!

ក៖ ចាំ!!

ខ៖
ចុងបញ្ចប់ញ៉ុមនៅ២០ឆ្នាំហាំអត់មានអីអោយញ៉ុមអីបន្តិចទេអោយញ៉ុមឈប់នៅហើយគ្មានគុណកម្លាំងចិត្តអោយញ៉ុមទេ!!

ក៖ ចាំ!!

ខ៖ ញ៉ុមថាអោយអ្នកឯងយកចុះ!!
ផ្ទះដីនៅលើហ្នូទល់មុខផ្ទះចាប់ហ្វួយអូនឯងដើរឡើងមើល!!អោយកូនប្រុសញ៉ុមនៅ
កាលហ្នឹងកូនប្រុសញ៉ុមនៅ កូនប្រុសញ៉ុមនៅអើរវាឈឺ
វាឈឺហ៊ីអញអត់មានលុយទេកូនឯងវាគ្រោះថ្នាក់ចរាចរណ៍បាក់ម្រាមជើងនេះហ៊
អញទៅខ្ចីលុយអ៊ីហ្អែង១០០០០០ជាងមកហើយចាំមើលបើម៉េចម៉ាមានលុយ
បើអញមានលុយសងយកសងគាត់ បើអត់លុយសងគាត់អញទៅធ្វើការអោយរួចលុយហ្នឹង ។

ក៖ ហ៊ីៗ!!

ខ៖ ដល់នេះទៅបងឯងមកហើយ
អើរអ៊ឺហាំហាចៃហាថ្ងៃសៅរ៍ញ៉ុមអត់ទាន់បានទៅទេទាល់តែថ្ងៃចន្ទ័ព្រោះអីថ្ងៃសៅរ៍គេប្រជុំជីរួមហាំ ដឹងគាត់ឆ្លើយតាមទរសព្ទ័ថាម៉េចទេ!!អើរបើថ្ងៃហ្នឹងមិនបានមកមិនបាច់មកទេ
គាត់និយាយប្រាប់ញ៉ុមថាអញ្ចឹងណាស់
បើមិនបាច់មកហើយចាំទទួលកូនញ៉ុមវាគ្រោះថ្នាក់អាជើងហ្នឹងមិនទាន់ជានោះ
ញ៉ុមទៅធ្វើការអោយគេនៅតាខ្មៅលក់ប្រដាប់បុណ្យនោះ!!

ក៖ ចាំ!!

ខ៖ ហង្ស សំពត់ងូត ស្បង់អីៗ

ក៖ ចាំចាំ!!

ខ៖ ហ្នឹង!!

ក៖ ស្លាដក់អីហ្នឹងហោ?

ខ៖ ហ្នឹងស្លាដក់ហ្នឹង ផ្ទះអំទូចញ៉ុមនៅបានមួយឆ្នាំនេះ!!

កៈ ចាំ!!

ខៈ ញ៉ុមយកលុយហ្នឹងមកព្យាបាលកូនជើង ជើងកូនញ៉ុមអាពៅគេហ្នឹងហិ។

កៈ ហ៊ីៗ!!

ខៈ អស់២០០ជាងហាំ!!

កៈ ចាំ!!

ខៈ អោយកូនទទេណាស់ ដល់ពេលយើងអត់ណាស់
១០០លុយខ្មែរឬក១០០០លុយខ្មែរវាមិនជួយយើងទេ!!

កៈ កូនហោ?

ខៈ ហ្នឹងហើយកូនបង្កើតហ្នឹង ហ្នឹងពេលញ៉ុមទៅវះនេះ នេះហិ
ញ៉ុមវះញ៉ុមពិការទេបានយកលុយ!!

កៈ វះអីគេវិញអ៊ំ?

ខៈ នេះពោះវៀនដុះខ្នែងហិ!!

កៈ តែអ៊ំកូនអ៊ំអត់ជួយវិញ?

ខៈ បានកូនញ៉ុមមួយនេះទេណាស់!!

កៈ ក្រោយហោ?

ខៈ កូនញ៉ុមប៉ុន្មាននាក់នេះ នេះកូនប្រុសញ៉ុមអាទីពីរនេះហិ។

កៈ ដល់ពេលអាមើលចិត្តអត់បានវិញ?

ខៈ អត់ទេ ទៅសួរយើងប្រពន្ធហិ ដេកនៅគ្រែនោះកៅអីនោះវាឈរពរកូននៅនេះទេ។

កៈ ចាំ!!

ខៈ វាឈរពីចម្ងាយយើងទេណាស់ ខ្ញុំពិនិត្យឈាមចង់អត់ទាន់ទៀតណាស់ ចង់ហួសហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ ចូលឡើងចង់ជ្រុលម៉ោង
គេមុនវះអញ្ចឹងគេពិនិត្យឈាមមើលរាវខាប់អីអីហាំ!!យើងអត់ទាន់ទេ!!គ្រាន់តែយកលុយវះអោយថ្លៃឈាមហើយយើងអត់បានពិនិត្យនាំទៅ
បើញុំមញាក់ឡើងបែកពពុះមាត់ហើយតែ៣ថ្ងៃទេណាស់ ខ្ញុំយប់ចេះតែស្រាវស្រាញ់ដែរ
ញ៉ុមមិនហ៊ានប្រាប់កូនថាធ្លូញឈឺដែរណាស់។

ក៖ ហ៊ឺៗ!!

ខ៖ ព្រលឹមឡើងយើងធ្វើនេះបែកញើសទៅដល់តែធូន់តើបានកូនប្រសារញ៉ុម
ឯងអាលែងអែរអង់អែរអង់ម៉ែខ្លាំងហើយ
អាអោយអាកូន៣ញ៉ុមហ្នឹងឧបទៅសម្តពផល្លីពេទ្យគេអត់អោយយើងមកទេណាស់ចង់យកយើងចូលវះទៀតញ៉ុមថាញ៉ុមមិនអាចវះបានភ្លាមៗទេញ៉ុមអត់ទាន់ពិគ្រោះជាមួយកូនញ៉ុមចុះយើងអត់លុយហើយយើងនៅជាមួយកូន កូនឯងមើលហើយកូនញ៉ុមចេញទាំងស្រុងហា!!

ក៖ ចាំ!!

ខ៖ ហើយម្លេះហើយយើងខ្លាចចិត្តគេ!!

ក៖ មានប្រពន្ធហើយតើហី?

ខ៖ មានហើយមានប្រពន្ធកូន២ !! នោះកូនញ៉ុមហើយនោះ។

ក៖ ចាំ!!

ខ៖ កូនប្រុសញ៉ុម!!

ក៖ ស្អាតៗ!!

ខ៖ នោះចៅហើយនោះ!!

ក៖ ហើយទៅណាឬក៏ទៅនៅភ្នំពេញ?

ខ៖ ហើយនេះបានកូនមួយប៉ុននេះទៀតហិ!!

កៈ ហុីស្អាតៗទៀតណាស់!!

ខៈ បានកូនស្រីមួយហ្នឹងហ៎!!

កៈ ចាំ!!ហើយឥឡូវពួកគាត់ទៅនៅភ្នំពេញទាំងអស់?

ខៈ ម៉ែក្មេកគេក៏មិនធម្មតាដែរកូនអើយ!!

កៈ ហ្ហ៎!!វាមានសំណាង តែប្រពន្ធវាកូនចិញ្ចឹមទេតែយាយនោះស្រលាញ់វាណាស់!!

កៈ ស្រលាញ់ៗ

ខៈ លុយគាត់ទេនេះខ្ញុំមកធ្វើផ្ទះនេះ!!

កៈ ចាំបានផ្ទះស្អាតទៀតហា!!

ខៈ ធ្វើខ្ញុំគាត់!!

កៈ ស្អាតម៉ងហើយនេះ!!

ខៈ ហើយសុទ្ធតែម៉ឺនហើយគាំតមកហុីបងឯងនៅជាមួយកូនកុំទៅណា!!

កៈ អូយឡើងល្អទៀត!!

ខៈ ចាំ!!ញុំមស្មាតតែវាធ្វើផ្ទះខ្ទម ថាលុយ១០០០០មិនដឹងយកមកធ្វើអីទេ!!ខ្ញុំគេអូនណាស់!!

កៈ ចាំ!!

ខៈ ហើយកាត់ប្រាក់ខែអោយគាត់វិញទេកូនណាស់!!

កៈ ហុីៗ!!

ខៈ មិនមែនធ្វើខ្លួនឯងស្ដឹមស្អែអីចឹងទេណាស់!!

កៈ បានអុំនៅត្រជាក់ស្រួលដែរនេះហ៎!!

ខ៖
ដល់ពេលខាងលើនោះដល់តែពេលគេឈប់អោយយើងនៅគេប្រគល់អាផ្ទះអោយអាកូនពៅ
ញ៉ុមនៅគេចង់យកលេសចង់អោយយើងចេញហ៎ាខ្លាចយើង!!

ក៖ ចា៎!!

ខ៖ យើងទាមទារមានអ្នកខ្លះនៅដីគេមួយរយៈ
ខ្ញុំនៅដីគេ២០ឆ្នាំគត់អូនខ្ញុំគ្មានយកប្រាក់ខែអី១០០ពុះជា៤ទេ។

ក៖ ចា៎ហើយក៏មិនទាមទារអីទៀត!!

ខ៖ ហើយគាត់ខឹងញ៉ុមត្រង់ញ៉ុមទៅខ្ចីលុយគាត់១៥០០០០ហ្នឹងហា៎!!

ក៖ ហ៊ឺៗ!!

ខ៖ គាត់ប្រាប់ថាបើថ្ងៃសៅរ៍អត់បានមកបងឯងមិនបាច់មកទេ
ខ្ញុំមិនខំរៀរទៅធ្វើការណោះទៅសងលុយគាត់
គាត់មកហើយសុទ្ធតែថាយើងហ្នឹងបោកគាត់ហ្នឹងហា៎!!

ក៖ ចា៎!!

ខ៖ គាត់ចង់យកលេសអោយយើងចេញហា៎២០ឆ្នាំដែលញ៉ុមអត់យកប្រាក់ខែហិ!!

ក៖ ហ៊ឺៗ!!

ខ៖ ញ៉ុមថាថៃគុណតែមួយខែតែ៥០០០០ទេ ២០ឆ្នាំថៃឯងគុណអោយញ៉ុមមើល
ហ៊ឺអាងកូនធ្វើមេធាវីអី ស៊ីពេក គេដេញគេចង់យកដាក់គុកហ្ន៎បានមានលុយតទេ។

ក៖ ចា៎!!

ខ៖ ហើយអាលុយ អាលុយកូនប្រសារក៏ធ្វើមេធាវីអាកូនបង្កើតក៏ធ្វើមេធាវីដែរ។

ក៖ ចា៎ហ្នឹងហើយហើយអ៊ំចេញពីហ្នឹងមក?

ខ៖  ហើយចេញមក ហើយលុយខ្មែរតែ១០០ពុះជា៤!!

ក៖ ចិត្តអាក្រក់ពេកហើយអ៊ំណោះ!!

ខ៖
ហើយអោយកូនញ៉ុមចេញហើយថាហ្អែងជួលផ្ទះទៅអញរូសផ្ទះ!!ហើយផ្ទះមានរូសណាមើល ហ្ន៎ចាក់សោរចោលហ្ន៎!!

ក៖ ហ៊ឺ!!

ខ៖ ហ្អែងចេញទៅជួលផ្ទះគេចាំអញជួយចេញថ្លៃផ្ទះ២ ៣ខែ!!ហើយកូនញ៉ុមទឹមតែនៅមយខ្លីពេលនេះទេណាស់!!អើរវាល្មមមួយឆ្នាំហើយពេលនេះ ហា!!

ក៖ ទុកផ្ទះហ្នឹងចោលទាល់តែឥឡូវទៅ?

ខ៖ ចាក់សោរ ហើយគេថាអត់ទៅផ្ទះ ?ហ្ន៎នៅគិតគូរមើកញូស់ហ្នឹងដល់ពេលណាទៀតទេ ទេ្វគុណដីអត់មានប្លង់ទេដីហ្នឹងហ្ន៎!!

ក៖ ហ៊ឺៗ!!

ខ៖ ដីញ៉ុមនាំគាត់មកកាប់ដីគេជំពាក់លុយគាត់ទេ ញ៉ុមមើលរហូតហា៎!!

ក៖ ចា៎ឥឡូវអ៊ំចូលដល់ជីវិតអាពាហ៍ពិពាហ៍វិញម្ដង ម៉េចការសិក្សាអីបានហើយខ្លះៗហើយ អ៊ីចឹងអ៊ំរៀបការជាមួយស្វាមីឈ្មោះអីគេវិញ?

ខ៖ ញ៉ុមហេកូនហេ?

ក៖ ចា៎!!

ខ៖ ខ្ញុំមិនបានរៀបអីស្រួលប្រួលទេ។

ក៖ គេរៀបអោយនៅក្នុងអាពតហើអី?

ខ៖ អត់ទេ។

ក៖ មុនការ មុនអាពតទៀតហេ?

ខ៖  ខ្ញុំហ៎ាកាលខ្ញុំ កាលញ៉ុមនៅប៉ុល
ពតខ្ញុំបែកទៅហ៎ាញ៉ុមមានគ្រួសារមួយប៉ុន្តែគេបាញ់ស្លាប់។

ក៖ ហ្វ៎អ៊ីចឹងអ៊ំមានស្វាមី២?

ខ៖  ចា៎!!

ក៖ ឥឡូវនិយាយពីស្វាមីដំបូងសិន។

ខ៖ មកស្លាប់!!

ក៖ ឈ្មោះអីគេ?

ខ៖  ឈ្មោះកែវ។

ក៖ អីគេកែវ?

ខ៖ អើរឪពុកគាត់ឈ្មោះហ៊ុន ។

ក៖ អញ្ចឹងហ៊ុន កែវ?

ខ៖ ហ្នឹងហើយ!!

ក៖ ហើយពេលហ្នឹងក៏គាត់ស្លាប់ចោលបាត់ទៅ?

ខ៖ ស្លាប់ចោល។

ក៖ ស្លាប់ពេលណា?

ខ៖  ស្លាប់ពេលអាពតបាញ់សម្លាប់ នៅ នៅពេលអាយើងចេញមកហើយហើយ។

ក៖ ចា៎!!៧៩(១៩៧៩)ហើយណោះហើយហើយហ្នឹង?

ខ៖ ហ្នឹងបាន នេះឪអាមួយហ្នឹងហ៎ាបាញ់ស្លាប់ក្នុងទឹក នៅកន្លែងនេះ
អីគេហៅស្ទឹគេហៅស្ទឹខាងនៅស្រុកគេហ្នឹងគេហៅទួលក្រសាំងដែរហ្នឹង តែទឹកនោះទឹក!!

ក៖ ទួលក្រសាំងយើងនៅនេះហ្នឹងហី?

ខ៖  មិននេះទេ!!

ក៖ នៅឆ្ងាយណាផ្សេងហេ?

ខ៖  នៅអីនឹងអាពតហ្នឹងហា៎!!នៅយើងចេញមក!!

ក៖ នៅឆ្ងាយណាខេត្តហ្ន៎?

ខ៖  ហ្នឹងហើយ!!

ក៖ អ្នកណាគេអ្នកបាញ់ស្លាប់?

ខ៖  អាពតវាអត់ទាន់ចេញអស់នោះ !!

ក៖ ហ្ន៎!!

ខ៖ ពេលយើងអត់ទាន់ចេញមកនោះ!!

ក៖ ហ៊ីអាពតបាញ់ប្រជាជនស្លាប់ទៀតទៅ?

ខ៖ បាញ់ទៅ វាចេញអត់ទាន់ផុតទេ វានៅពេញ វានៅពេញក្នុងបន្ទាយស្លឹកនៅឡើយហ្នឹង!!

ក៖ ហ្ន៎!!

ខ៖ ហើយណេះទៅរកម្ហូបរកអីអោយប្រពន្ធហូបហ្នឹងហា៎!!

ក៖ អូយ!!

ខ៖ ទៅយកស្រូវហា៎!!ហើយអើយអាកូន ឪអានេះទឹមតែចេះអង្គុយហ្នឹង
ញ៉ុមទឹមចេញពីអាពតមកញ៉ុមមានកូនខ្ចីហា៎!

ក៖ អ៊ីចឹងអ៊ំជាមួយប្តីមុនមានកូនប៉ុន្មាននាក់?

ខ៖  តែមួយទេ!!

ក៖ តែមួយទេហេ!!

ខ៖ តែមួយឪអានេះ!!!

ក៖ ចាំ!!

ខ៖ កូនទីមួយហាំ!!

ក៖ ចាំ!!

ខ៖
ហ្នឹងហើយហើយដល់ហើយទៅបានបែកពីអាពតមកបានស្លាប់ទៅបានញ៉ុមបែកពីអាពតមក!!មកដល់៧៩(១៩៧៩)នេះញ៉ុមបានគ្រួសារស្រុកកំនើតគេនៅសៀមរាបអង្គរ។

ក៖ ចាំ!!

ខ៖ ឥឡូវមានគ្រួសារនៅព្រែកថ្លឹងហ្នំ!!កូនច្រើនទៀត!!

ក៖ ឥឡូវឈប់និយាយពីប្តីដំបូងសិន ម៉េចបានជួបគ្នាដំបូងហាំ?

ខ៖  កាលប្តីញ៉ុមដំបូងហ្នឹងហាំ!!

ក៖ ជួបគ្នាពេលណា?

ខ៖ អើយជួបគ្នានៅពេលប៉ុល ពតគេចាប់រៀបអោយ។

ក៖ ហ្នំរៀបនៅក្នុងជំនាន់ប៉ុល ពតទេហេ?ហើយមានធ្លាប់ស្រលាញ់ទេ?

ខ៖ អត់មានចាប់អារម្មណ៍ទេ លោកអើយ !!អាសូរតិចគូរ១៥គូរ!!

ក៖ រៀបអោយអញ្ជឹងទៅ?

ខ៖  ហ៊ីប្រកែកអត់បានទេណាស់!!

ក៖ ប្រកែកយកទៅសម្លាប់ចោលម៉ងអ៊ំណោះ?

ខ៖ ហ៊ីអត់បានទេរៀបនៅប៉ុល ពតហាំ រៀបញ៉ុមគ្រាន់បើហើយរៀបគេ គេថាអត់មាននេះទេ
រៀបញ៉ុមបានដាំបាយរៀបញ៉ុមសុទ្ធបបរ។ក៖ ចាំ!!ខ៖ សហាករណ៍គេហាំ!!

កៈ ហ៊ឺៗ!!

ខៈ បានដាំបាយ ថាមិត្តឯងយកទៅអត់មាននេះទេ!! ឥឡូវ១៥គូរ មិនដឹងណាណីទេ !!តែមិនឯងប្រកែកនឹងទើសអង្គការអត់បានទេ។

កៈ ចាំ !!យកទៅ!!

ខៈ បានមួយហ្នឹង!! មួយហ្នឹងស្រាប់តែទម្ងន់នៅអាពត ដល់តែកូនហ្នឹងកើតបាន៥ខែ កូនញ៉ុមកើតបានតែ៥ខែទេណាស់ហាំ!!

កៈ ចាំ!!បីមកហា!!

ខៈ អាគេវ៉ៃបែកបានហាំ វៀតណាមជួយបីញ៉ុមឆ្លងទឹកតើ!!

កៈ ចាំ!!

ខៈ កកាបនេះ ស្ពានកាកាបអាហ្នឹងគេហៅកាកាប។

កៈ ហ្នឹងហើយ!!

ខៈ ហ្នឹងគេចេញមកពីពោធិ៍សាត់មកហាំ!!

កៈ ចាំ!!

ខៈ
ញ៉ុមថាវេទនាហើយប្អូនថ្លៃមកតាមឡើងរយោង។ស្រុកកំណើតរបស់ប្ដីញ៉ុមនៅកោះធំហាំ!!កៈ ចាំ!!

ខៈ ខ្សែចិនទៀតតាគាត់អត់ចេះខ្មែរទេ!!តែគាត់ស្លាប់
បងប្អូនគេនៅពីរគ្រួសារនៅសហរដ្ឋអាមេរិច។

កៈ ហ្នំចេញពីប៉ុល ពតទៅបានទៅណោះទៅហោ?

ខៈ អាកូនបងគេហ្នឹងនៅសហរដ្ឋឪពុកម្ដាយក្មេកញ៉ុមអត់ដឹងផងហ្នឹង!!

កៈ ហ៊ឺៗ!!

ខ៖ បែបគេអាពេលបែកពីប៉ុល ពតទៅគេចេញទៅរួចហាំ!!ហើយគេបានរៀនជ្រៅជ្រះដឹងទេ
នៅអាមេរិចហាំ!!ហើយមួយទៀតនៅប្អូនថ្លៃទេ
នៅអាពតជាមួយញ៉ុមហើយតែដល់ពេលគេបែកប៉ុល ពត
គេចេះទៅទៅនៅកាណាដាហ្ហ៎!!ទៅកាណាដាគេទៅជាមួយម្តាយមីងគេហាំ!!

ក៖ ចាំ!!

ខ៖ ជាមួយកឹមគេហ្នឹង ចេះជួបបងគេហ្នឹងបងគេយកទៅទៅ
ទៅផ្ញើរទៅចិញ្ចឹមម្តាយធម៌ចិញ្ចឹម។

ក៖ ចាំ!!

ខ៖ ឥឡូវនៅហ្នឹង២នាក់ អាមេរិចហ្នឹង!!

ក៖ ចុះម៉េចបានជួបស្វាមីក្រោយអុំ?

ខ៖  ស្វាមីក្រោយហោ?ជួបគ្នានឹង៧៩(១៩៧៩)ហ្នឹងតើ!!

ក៖ ហ្ហ៎!!

ខ៖ ញ៉ុមទៅថៃ ញ៉ុមទៅថៃជាមួយគ្នា
គេថាទៅរកស៊ីនៅថៃហ្អែងចេះធ្វើបាយធ្វើទឹកអញ្ចឹងហ្អែងលក់តែបាយទៅ
ទៅជាមួយគេទៅស្រីៗច្រើនណាស់។

ក៖ ចាំ!!

ខ៖ គេធ្លាក់ទៅហ្ហ៎!!

ក៖ ចុះពេលទៅថៃហ្នឹងឆ្នាំ៧៩(១៩៧៩)ហ្នឹងដែរហោ?

ខ៖  ហ្នឹងយើងមកវិញ៨០(១៩៨០)ហើយ
ញ៉ុមទៅពី៧៩(១៩៧៩)មែនប៉ុន្តែអើរអញ្ចេះទៅ៧៩(១៩៧៩)ដល់ញ៉ុមទៅបានតែប៉ុន្មានខែតើ
ញ៉ុមមកវិញ ។

ក៖ ចាំ!!

ខ៖ ដូច៧ខែហើអីទេ!!មកវិញយើងចូលឆ្នាំ៨០(១៩៨០)ហាំ!!

ក៖ ចាំ!!

ខ៖ យើងចូលមកដល់ស្រុកវិញហាំ!!

ក៖ ចាំ!!

ខ៖ ហ្នឹងហើយ!!

ក៖ ហើយជួបប្តីពេលនៅណោះឬក៏ពេលមកនៅណេះ?

ខ៖ ជួបនៅហ្នឹង។

ក៖ ៧៩(១៩៧៩)នៅហ្នឹងហ្នឹង?

ខ៖  ជួបនៅហ្នឹងគាត់ជាងថតរូបហើយញ៉ុមមិនចាប់អារម្មណ៍ញ៉ូមទៅ!!

ក៖  គាត់មេម៉ាយទេ?

ខ៖ អត់ទេកំលោះ។

ក៖ ហេកំលោះមកស្រលាញ់មេម៉ាយហេ?

ខ៖  ហ្នឹងហើយអ៊ីចឹង ពួកម៉ាក់មិត្តភក្តិគាត់ថា
ចោរម៉ាយអានេះគិតទៅអានេះចាប់អារម្មណ៍ភ្លាមហាំ!!អ្នកភ្នំពេញហាំ!!

ក៖ ចាំ!!

ខ៖ គេណោះគេស្លៀកពាក់របៀបថៃ។

ក៖ ហ៊ឺៗ!!

ខ៖ យើងចូលទៅថ្មីគេមិនចាប់អារម្មណ៍
ម្នាក់ហ្នឹងទឹមតែមកពីស្រុកខ្មែរថាអោយយើងអញ្ជឹងហាំ!!ញ៉ូមទៅមុជទឹកហាំ!!ម្នាក់ហ្នឹងទឹមតែម

កពីស្រុកខ្មែរហិហើយទៅដល់ណោះបានគេអោយយើងស្លៀកអាសំពត់សឹងបង្កក់ដូចថៃអីចឹតងហាំ!!

ក៖ ចាំ!!

ខ៖  ហើយពាក់មួកសំបុកវាហ្នឹង!!

ក៖ ហ៊ឹៗ!!!

ខ៖ ចូលទៅដីថៃ ដល់នេះទៅគេទៅសុំច្បាប់ជំរុំរៀបចំ គេយកសុទ្ធតែទ័ពយកមកធ្វើរោងធ្វើអី !!

ក៖ ហ៊ឺ!!

ខ៖
ហ្នឹងហើយគ្រាន់តែថាវាមានមេក្រូមានអីអញ្ចឹងតែវាមិនហឹកហ៉ៅកដូចយើងឯណោះទេមីកូនមីប្អូនចិញ្ចឹមញ៉ុមមួយឈ្មោះមីចំរើន ចំរើនហ្នឹង ទៅជាមួយគាត់ហ្នឹងគាត់ថា
ហោ!!ចុះគាត់កាលពីនៅអាពតញ៉ុមមិនជួយគាត់!!

ក៖ ចាំ!!

ខ៖ គាត់ប្តីមេព្រៃ មេព្រៃដល់តេគាត់ដាំបាយក្នុងកំសៀវហាំ!!

ក៖ ហ៊ឹៗ!!

ខ៖
ដាំបាយក្នុងកំសៀវគេចាប់គាត់ចាប់គាត់ញ៉ុមគ្រាន់តែថាណែមិត្តឯងមើលហ្ន៎!!បងអើយបងអនុគ្រោះម្តងទៅ ហើយបើលើកក្រោយចាំញ៉ុមធានាហើយហ៊ានយកខ្លួនឯងទៅធានា។

ក៖ ហ៊ឺ!!

ខ៖ ហើយគាត់ហ្នឹងតែម្តងហ្នឹង
គាត់លែងហ៊ានបានជំនាន់ហ្នឹងញ៉ុមគេអោយទៅកិនអង្ករបានអង្ករតើ។

ក៖ ចាំ!!

ខ៖
បានឈប់ទៅខ្លាចគេយកវ៉ៃចោលកូនស្រី២ហ្នឹងហើយប្ដីមេព្រៃគេយកវ៉ៃចោលហើយហ្នឹង។

ក៖ ហើយអ៊ីចឹងរៀបការ!!

ខ៖ ហើយជួបគាត់ហ្នឹង ទៅហ្នឹងជួបហ្នឹងជួបគាត់ គាត់ហ្នឹងអោយយើងនៅជាមួយ។

ក៖
ហើយម៉េចបានស្រលាញ់ប្ដី?ពេលហ្នឹងម៉េចគេចាប់ផ្ដុលម៉េចបានក៏លួចស្រលាញ់អីគ្នាហើយ?

ខ៖ អត់ទេកាលហ្នឹងយើងបែកពីងណោះមក ចាំមើលណាស់!!

ក៖ ចាំ!!

ខ៖ អាហ្នឹងនេះហើយមិនគាត់ស្លាប់។

ក៖ ចាំ!!

ខ៖ ស្លាប់ហើយដល់អាពេលញុំមទៅរកស៊ីថៃនេះបានបានអាតានេះ!!!

ក៖ ចាំ!!តែម៉េចបានជួបគ្នា?

ខ៖  ជួបគ្នាអីបើគាត់នៅក្នុងជំរុំ បើគាត់ដើរថតរូបដែរ ហើយគាត់!!

ក៖ ហើយឃើញក៏ស្រលាញ់ទៅ?

ខ៖  ហើយខ្ញុំម៉ោង៧ ម៉ោង៦ ៧គេអោយបង បងចំរើនហ្នឹងអោយញុំមចិតម្នាស់លក់។

ក៖ ចាំ!!

ខ៖ មួយចំនិត៥បាត់ មួយចំនិត៥បាតនោះ!!

ក៖ ហ៊ឺៗ!!

ខ៖ គេអុជភ្លើងទៀនលក់តើអូន។

ក៖ ចាំ!!

ខ៖ នៅក្នុងជំរុំហាំ!!ម្យ៉ាងដែរ!!

ក៖ ហើយពេលហ្នឹងបានទៅនៅជុំរុំម៉េចក៏អត់ព្រមភៀសខ្លួនទៅស្រុកគេអីវ៉ាន់ដែរ?

ខ៖ មានលុយឯណាទៅ។

ក៖ ហ្ហ៎ដល់មានលុយទៀតបានបានទៅហេ?

ខ៖
ទៅនេះគេសុទ្ធតែមានលុយទៅហាំ!!ក៏មញ៉ុមរើសបានពេជ្រប៉ុន្មានគ្រាប់ហាំឪពុកក្មេកគាត់ទៅហាំ!!

ក៖ ចាំ!!

ខ៖ គាត់សួរញ៉ុមសួរមីប្អូនមួយវាកើតខាន់លឿងវាអត់បានទៅ វាអត់បាន បានទៅតែមីប្អូនហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ ហ៊ីមីរ៉ុន មីរ៉ូហ៊ីញ៉ុមអត់ទៅទេ ទៅជាមួយសោរហើយ ញ៉ុមទៅស្រុកជាមួយសោរហើយ
មីនោះឯង ហើយចុះវាឈឺ ហើយមីនោះវាមិនមែនឈឺឯណាទៅហើយហើយខ្មៅក្រញែស
ហើយមីហ្នឹងគេចេះតែថាកូនញ៉ុមគេមិនមែនថាប្អូនថ្លៃទេ!!ម៉ែហ្អែងទៅណាស់
កាលញ៉ុមស្នាក់នៅពោធិ៍សាត់ហាំ!!

ក៖ ចាំ!!

ខ៖ ម៉ែញ៉ុមនៅទីនោះ នោះផ្ទះញ៉ុមម៉ែញ៉ុមស្លាប់ម៉ែញ៉ុមអីផ្តាំ មានតែកូនឯងទេ!!

ក៖ ចាំ!!

ខ៖ ក្រុងកូនហ្នឹងម៉ែអត់បានរស់នៅទេ ឪពុកក្មេកញ៉ុមម៉ែក្មេកញ៉ូមស្លាប់នៅអាពតទាំងអស់!

ក៖ ចាំ!!អញ្ចឹងអ៊ំឪពុកហាំប្តីអ៊ំក្រោយហ្នឹងជួបគ្នានៅជុំរុំការនៅជំរុំហ្នឹងទៅ?

ខ៖ ចាំ!!!

ក៖ អ៊ិចឹងការនៅក្នុងទឹកដីថៃទេអ៊ីចឹងហេ?

ខ៖  ការនៅជុំរុំ។

ក៖ អីចឹង១៩៧៩អុំការហ្នឹង?

ខ៖ ហ្នឹងហើយ។

ក៖ ហ្នឹងហើយមក!!

ខ៖ ហ្នឹងហើយ ប្រធានជុំរុំហ្នឹងគេអោយយកមេក្រូមកដាក់!!

ក៖ ចាំ!!

ខ៖ គេអោយទ័ពនៅក្នុងជុំរុំហ្នឹងមកធ្វើរោងធ្វើអីអោយយើង!!

ក៖ ហ៊ឺៗ!!

ខ៖
គ្រាន់តែថាយើងអត់មានផ្កាស្លាអីទេគេបាចចាក់ផ្កាលើហើយមីក្មួយកូនអាអ្នកអោយញ៉ុមនៅជួយលក់ឥវ៉ាន់ហ្នឹងហាំវាយកផ្កាក្រដាសយកមកធ្វើសក់!!

ក៖ ហ្ហ៎!!

ខ៖ ថតមកតើអូន អាថតភ្លាមបានភ្លាមហ្នឹងយកមក!!

ក៖ ហ្ហ៎អញ្ចឹងទៀត?

ខ៖ ហ្នឹងហើយ!!ហើយអាអ្នកស្រុកនៅហ្នឹងម៉ាអាអ៊ិចឹងទៅថតនៅហាងក៏បានដែរ
ទៅថតហាងអាណាក្នុងព្រៃ ថតហើយ គាត់ គាត់ជាងថតរូបពូកែណាស់ជំនាញ!!

ក៖ ចាំហើយចុះអុំម៉េចបានបានបែកគ្នាអីចឹង?

ខ៖  បែកគ្នាគាត់មានស្រី ។

ក៖ ប៉ុន្មានឆ្នាំបានគាត់ទៅមានប្រពន្ធក្រោយទៀត?

ខ៖ ហ៊ីញ៉ុមមានកូន២ ៣ហើយហ្នឹង។

ក៖ ចាំ!!

ខ៖ ហើយបើកូនប្ដីញ៉ុមមួយ។

ក៖ ចាំ!!

ខ៖ ហើយកូនគាត់ពីរ!!

ក៖ ចាំ!!

ខ៖ នេះអាមួយនេះមួយអាមីស្រីនោះ លក្ខិណាមួយ រដ្ឋាមួយ!!

ក៖ អ៊ីចឹងឥឡូវកូនអ៊ំជាមួយប្ដីក្រោយ៣នាក់អញ្ចឹង?

ខ៖ ៣នាក់ហើយកូនញ៉ុមនោះមួយ!!

ក៖ ហើយកូនមុននោះមួយ!!ចាំ!!

ខ៖ ហ្នឹងហើយ!!

ក៖ អញ្ចឹងអ៊ំកូនមុននោះឈ្មោះអីគេខ្លះ?បងគេឈ្មោះអីគេ?កូនប្ដីមុនឈ្មោះអីគេ?

ខ៖ កូនប្ដីមុនញ៉ុមដាក់ត្រកូលគាត់នេះហ្នឹង ឡាច កែវ។

ក៖ ឡាច កែវ!!

ខ៖ ហ្នឹង!!

ក៖ ដល់ពេលកូនទី២?កូនមកប្ដីមុនបងគេហ្នំ?

ខ៖ ទីពីរនេះ!!

ក៖ ប្ដីក្រោយនេះ?

ខ៖ អើរនេះ ឡាច វិបុល។

ក៖ ដល់ពេលទី៣?

ខ៖  ឡាច លក្ខិណា!!

ក៖ ហើយដល់ពេលទី៥?

ខ៖ ឡាច រដ្ឋា!!

ក៖ ចាំអីចឹងកូននៅទាំងអស់អីចឹង?

ខ៖ ហ្នឹងហើយ!!

ក៖ តែកូនមានអ្នកណាគេទៅនៅជាមួយនេះណាហី នៅជាមួយ មានអ្នកណាទៅជាមួយ?

ខ៖  គេមានគ្រួសារ។

ក៖ អត់មានអ្នកណាគេទៅនៅជាមួយឪទេហោ?

ខ៖ អត់ទេ មុនដំបូងកាលញ៉ុមលែងគ្នាមានមានអ្នករត់ទៅនៅជាមួយឪ
នៅអត់កើតមកនៅជាមួយញ៉ុមវិញ។

ក៖ ហ្ន៎!!

ខ៖ ញ៉ុមបើមួយសិទ្ធម៉ាសេរី!!

ក៖ អីចឹងអ៊ំគាត់ការបានប៉ុន្មានឆ្នាំបានគាត់មានស្រី?កូនដឹងតែបីហើយបានមានស្រីមែនទេ
ឆ្នាំប៉ុន្មានបានគាត់ទៅមានស្រីចោលអ៊ំ?

ខ៖ គាត់ញ៉ូមបានកូន៣ហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ កូនស្រីញ៉ូម កូនស្រីញ៉ុមមីនោះ មើលញ៉ុមត្រូវរបស់គាត់ គាត់ស្រលាញ់ស្រីធ្វើញ៉ុមហាំ!

ក៖ ហ៊ឺៗ!!

ខ៖ ធ្វើម្តង២នាក់ហាំ!!

ក៖ ចំ!!ខ៖ កុំបានមាញ៉ុមមើលហា៎!!មីហ្នឹងកូនស្រីញ៉ុមពៅហ្នឹងហា៎ បានអាយុតែ៩ខែទេ។

ក៖ ហ្ន៎ៗ!

ខ៖ ញ៉ុមលែងស្គាល់កូនពៅហ្នឹងទាំងអស់!!

ក៖ ចុះឥឡូវកូនពៅហ្នឹងអាយុប៉ុន្មានហើយ?

ខ៖  កូនពៅ កូន២ កូន៣ហើយ!!

ក៖ អាយុប៉ុន្មានហើយ?

ខ៖  គ្រមុំហើយ!!ហ៊ឺមិនមែន២០ទេ ឆ្នាំខាល។

ក៖ ៣០ហើយហ្នឹងហី?

ខ៖ ៣០ជាងហើយ!!!បើវាកូនក្រមុំពីរហើយ!!ក៖ ចា៎!!ខ៖ កូនក្រមុំពីរកូនប្រុសមួយទៀតហើយ!!

ក៖ ហ្ន៎អញ្ចឹងឥឡូវ៣០ជាងហើយហ្នឹងហ្ន៎!!

ខ៖ ចា៎!!៣០ជាង!!

ក៖ អញ្ចឹងគាត់មានប្រពន្ធចុងតាំងពីកូននៅអាយុ៣០ជាងហាកូននៅ៩ខែ!!

ខ៖ កូន៩ខែហ្នឹងនៅកំពុងញ៉ុមឈឺហ្នឹង គាត់ហ្នឹងហើយកូនតាំងនៅ៨
៩ខែញ៉ុមដឹងគាត់មានស្រីតាំងពីកូននៅក្នុង៧ខែហ្ន៎!!

ក៖ ហ្ន៎!!នៅក្នុងពោះណោះ?

ខ៖ ហ្នឹងហើយតែញ៉ុមអត់ចាប់អារម្មណ៍ទេ ញ៉ុមនឹកឃើញថាក្មួយ ជាប់ក្មួយយើងដែរ
វាហៅយើងតែមីងមីង ឥឡូវនៅយកហ្នឹង!!

ក៖ ហ្នឹង មួយដែលធ្វើអំពើរហ្នឹង?

ខ៖ មួយហ្នឹងអត់ធ្វើទេ ធ្វើស្រីមួយទៀតមាន
គាត់នៅឈរកុងត្រូលគាត់មានគេស្រលាញ់ច្រើនពេក!!

កៈ ហ្ហ៎!!

ខៈ ដល់យកគេមកអោយគេដាំបាយស្លរ ស៊ីមិនដឹងវាដាក់អីអោយយើង
វាដាក់នៅក្នុងស្កូរត្នោតហាំ!!យកពីកំបូលមក
គាត់ឈរនៅកុងត្រួលកាំបូលហាំ!!អូយគាត់ឈរបាន៧ខែញ៉ុមធ្វើបុណ្យបច្ច័យបួនម៉ង
គាត់បបួលញ៉ុមទិញម៉ូតូញ៉ុមថាទេ ធ្វើផ្ទះញ៉ុមថាទេ
ព្រោះអីរបស់នេះរបស់លោកឯងចាប់របស់គេ!

កៈ ហ៊ឺ!!

ខៈ អ៊ីចឹងញ៉ុមធ្វើបុណ្យនេះដើម្បីរំដោះកម្មពៀរកុំអោយជំពាក់របស់គេណាស់!!
គេទិញយកមកគេចង់ចំនេញចង់អីយើងអំណាចបញ្ជាថ្នាក់លើមែនប៉ុន្តែជាប់កម្មពៀរតាមញ៉ុម
តើ!!ញ៉ុមធ្វើបុណ្យបច្ច័យបួនភ្លាម។

កៈ ចាំ!

ខៈ អត់ទាន់មានជាងថតរូបបានទេអូនណាស់ មួយហ៊ឹកហ្នឹងហាំ!!

កៈ ចាំ!!

ខៈ តែទូរទស្សប៍យើងហ្នឹងអត់មានផង យើងមានតែមួយៗៗៗទេ!!

កៈ ហ្នឹងហើយជំនាន់ហ្នឹងមុនហ្ហ៎!!

ខៈ ហ្នឹងហើយហើយញ៉ុមហិផ្ទះជញ្ជាំងកក់ដំបូលស្លឹក អ្នកស្រុកព្រែកកំពឹសគេនិយាយថាងាប់
ហើយកូនញ៉ុមអាបងហាំ
ចាប់ពីអាយុ១៣ឆ្នាំហា១៣ឆ្នាំ១៩ឆ្នាំហាំស្រីរៀនស្រលាញ់ឡើងថ្នាក់រហូត។កៈ ចាំ!!ខៈ
វារៀនបានប៉ុន្មានឆ្នាំគ្រូអោយផ្លូសម៉ងវារៀនពូកែហាំ!!

កៈ ហ៊ឺៗ!!

ខៈ ដល់ពេលញ៉ុមបែកគ្នាអញ្ចឹងទៅវាខូចចិត្តវាអត់រៀនលែងបានរៀនកើតទៅណាស់។

កៈ ហ៊ឺៗ!!

ខ៖ ឪអាហ្នឹងហាំរៀនពូកែណាស់ អាហ្នឹងខ្សែស្រលាយអ្នកកោះធំណាស់។

ក៖ ចាំ!!

ខ៖ រៀនពូកែណាស់!

ក៖
ចាំនិយាយអីចឹងអំម៉េចបានគាត់ទៅមានស្រីមានអីអញ្ចឹង?គេដាក់អំពើឬក៏គាត់ស្រលាញ់គេដោយចិត្តឯង?

ខ៖ ហុីដល់តែស្រីតែវាស្រលាញ់យើងវាធ្វើហើយកូន។

ក៖ ចាំ!!

ខ៖ មុនដំបូងអត់អីទេតែក្រោយមក!!

ក៖ តែឥឡូវមានកូនក្រោយទៀតហើយហោ?

ខ៖ ឥឡូវនេះមានកូនក្រមុំ កូនក្រមុំកូនកំលោះពីរអាកូនតូចៗ ៤ ៥។

ក៖ នៅជិតៗនេះតើហីអំហី?

ខ៖ ហុីនៅក្នុងភូមិហ្នឹងដែរហ្នឹង!!!

ក៖ ប្តីឈ្មោះអីគេប្តីក្រោយ?

ខ៖ ហុីឈ្មោះតាខន។

ក៖ អីគេខន?

ខ៖ ឡាច ខន។

ក៖ ឡាច ខន!!

ខ៖ ហុីៗ!!

ក៖ ហុីទៅអញ្ចឹងទៅណោះ?

ខ៖ ចាំ!!

ក៖
ហើយចោលកូនចោលប្រពន្ធណោះខ្លួនឯង!!អំពីបាកចិត្តប៉ុន្មានទៅកូនអើយប្តីទៅចោលលបាត់
នេះ??

ខ៖ ហ៊ីអ្នកភូមិព្រៃកថ្លឹងគេសរសើរញ៉ុមហាំ!!

ក៖ ម៉េចបានសរសើរវិញ?

ខ៖  ហ៊ីអញសរសើរ
សរសើរម៉េច!គេសរសើរថាក្រៅពីហ្អែងគេចងករគេសម្លាប់ខ្លួនបាត់ហើយ!!

ក៖ ហ៊ីៗ!!

ខ៖ ញ៉ូមថាញ៉ុមមិនសម្លាប់ខ្លួន!!

ក៖ ដោយសារប្រុស!!

ខ៖ ហ្នឹងហើយ ញ៉ុមអត់សម្លាប់ខ្លួនទេ ញ៉ុមចាំមើលអ្នកឯងហ្នឹងទៅជា!!

ក៖ យ៉ាងម៉េចទៅហេ?

ខ៖  ដូចជាកម្មពៀរដែរ។

ក៖ ម៉េចវិញអ៊ំ?

ខ៖ ផឹកស្រវឹងអញ្ចឹងដួលដាច់អាសរសៃរនេះ!!ឥឡូវនិយាយអត់ច្បាស់!!

ក៖ អោយប្រពន្ធក្រោយហ្នឹងមើលទៅ?

ខ៖  ហ្នឹងហើយ និយាយអត់នេះណា គាត់
គាំតស្បថជាមួយញ៉ុមហាំ!!កាលហ្នឹងហាំញ៉ុមថាខ្ញុំហាខ្ញុំអត់ចូលចិត្តទេ
មុននឹងខ្ញុំការយើងត្រូវខសន្យា។

ក៖ ពេលការហ្នឹងហេ?

ខ៖  ព្រោះអីអ្នកឯងនៅលីវញ៉ុមមានកូនមួយ!!

ក៖ ហ៊ីៗ!!

ខ៖ អញ្ចឹងអ្នកឯងមនុស្សធំញ៉ុមនិយយាអោយហើយ មនុស្សធំអត់វ៉ៃនឹងដំបងទេ
វ៉ៃនឹងសំដីបានហើយណាស់!!

ក៖ ចាំ!!

ខ៖ មនុស្សធំមិនមែនកូនក្មេងវ៉ៃនឹងដំបងវ៉ៃនឹងរំពាត់ទេណាស់!!អញ្ចឹងបើញ៉ុមខុសអីប្រាប់ញ៉ុម
ណោះអូនឯងខុសអានេះមួយខុសអានេះមួយ
អត់មានខុសដៃយកដៃខុសជើងយកជើងទេខ្ញុំអ៊ីចឹងដែរលោកឯងខុសបើសិនជាញ៉ុមជេរប្រមា
ថលោកឯងមួយមាត់
ញ៉ូមជេរម៉ែលោកឯងតែមួយម៉ាត់លែងក្បាលញ៉ុមចោលភ្លាមញ៉ុមអត់អោយទ្រាំទ្រពាក្យញ៉ុមប្រ
មាថអ្នកឯងទេ!!

ក៖ ចាំ!!

ខ៖ ហើយខ្ញុំអញ្ចឹងដែរ តែខ្ញុំខុសថាហ្នូអត់មានទាន់រកខុសត្រូវអីទេ
ញ៉ុមយកដំបងយកដៃអីវ៉ៃញ៉ុមអត់បានទេ
ទះញ៉ូមតែពីរដៃហាំលោកឯងចូលអត់ចុះទេហិ!!លោកឯងអត់ចុះញ៉ុមចុះ!!

ក៖ ហ៊ីៗ!!

ខ៖ អត់មានប្រមាថអត់មានអាម៉ឹងប្តីញ៉ូមសរសើរញ៉ុមរហូតហាំ!!គាត់នឹកឃើញខុស!!

ក៖ ហើយដល់ពេលម៉េចគាត់នឹកឃើញម៉េចក៏ដល់ពេលគាត់សន្យាជាមួយអ៊ំគាត់ថាម៉េច?

ខ៖ ឥឡូវជេរគេដេញគេវ៉ៃគេដូចគោដូចក្របីអញ្ចឹង។

ក៖ វ៉ៃប្រពន្ធក្រោយហ្នឹង?

ខ៖ ហ្នឹងហើយ ។

ក៖ ហ្នឹងហើយសមមុខហើយយកប្តីគេអញ្ចឹងហើយ!!

ខ៖  បងវរគាត់នៅក្នុងស្រុកហ្នឹងហ្អែងសំណាងហើយ!

ក៖ ហើយគាត់មានសន្យាអីជាមួយអ៊ំទេពេលហ្នឹងហីគ្រាន់តែអ៊ំអ្នកនិយាយ?

ខ៖  ដាក់សន្យា។

ក៖ ថាអត់ធ្វើបាបអ៊ំទេហោ?

ខ៖ ហ្នឹងហើយអត់ធ្វើទេឆ្លើយពិតប្រាកដ។

ក៖ ហ៊ឺ!!

ខ៖ គាត់ថាញ៉ុមពូកែចាំណាស់!!ញ៉ុមថាហ៊ឺមនុស្សហា៎!!

ក៖ សន្យាធំណាស់ពេលហ្នឹង!!

ខ៖ អត់បាច់ទៅស្បថអីណាធំដុំទេ
យើងនិយាយអីចឹងបើស្រលាញ់ញ៉ុមកាន់អាពាក្យស្បថអោយកាន់អោយជាប់!!

ក៖ ហើយដល់ពេលឥឡូវម៉េច ធ្លាក់លើគាត់ឬក៏ម៉េចអ៊ំ?

ខ៖ ហើយដល់ពេលទៅគាត់ទៅអង្វរញ៉ុមថាអើយឯងអើយ
ញ៉ុមអើយយកប្រពន្ធទៀតទៅហើយអោយោមានផ្ទះធំទ្រនំខ្ពស់ញ៉ុមអត់មានដាក់ទំនាយទេ!!

ក៖ ហ៊ឺ!!

ខ៖ គេក៏មានផ្ទះធំទ្រនំខ្ពស់មែនហា៎!!

ក៖ ហ៊ឺ!!

ខ៖ ហើយគាត់សន្យាថាជាមួយញ៉ុមទៀតថាខុស គាត់ឈប់យកហើយបើគាត់យក
បើញ៉ុមលែងម៉ែអាបុលឯងញ៉ូមអត់យកប្រពន្ធនៅស្រុកនេះទេ
បើញ៉ុមយកប្រពន្ធនៅស្រុកនេះអោយញ៉ុមស្លាប់នឹងឡានបុក។

ក៖ ហ៊ឺៗ!!

ខ៖ ជិះម៉ូតូគៀរនៅហ្នឹងព្រែកហូរហ្នឹង ប៉ុន្មានចូលមួយខែហាំ!!

ក៖ ហើរ!!

ខ៖ បុកគ្នានៅព្រែកហូរហិឡានគៀរ។

ក៖ អាហ្នឹងដូចជារបៀបថាទំនាយរបស់ខ្លួនឯងហាំ!!

ខ៖ ខ្លួនឯងស្បថខ្លួនឯងធ្វើអី!!

ក៖ ហ្នឹងហើយអ្នកណាគេហៅអ៊ំឯងអោយមកស្បថ!!អ្នកណាគេហៅមកស្បថ!

ខ៖
ហើយថ្ងៃទៅហាំ!!អត់មានក្រដាសស្នាមណាអោយត្រឹមត្រូវទេចង់ភ្លាមមកស្រលាញ់មីក្មួយនេះ
រួចទៅអោយញ៉ុមទៅផ្តិតមេដៃអោយសុំមេភូមិធ្វើក្រដាសសៀវភៅធម្មតាហ្នឹងហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ សរសេរទៅ
ហ៊ីផ្តិតមេដៃអោយញ៉ុមផ្តិតបានញ៉ុមថាអូខេមកក្រែមញ៉ូមដាក់ប៉ិបហ៊ីមានលុយខ្ញី៣០០០០ទៀត មកតាមផ្លូវណាទៅតាមផ្លូវហ្នឹងវិញអត់មានលុយអោយខ្ញីទេ។

ក៖ ហ៊ឺ!!

ខ៖
របស់ហាំខ្សែករបស់នៅហ្នឹងដៃហ្នឹងនេះញ៉ុមប្រគល់អោយទៅលោកឯងទាំងអស់មួយលីក៏ញ៉ុមអត់យកផង កុំអោយថ្ងៃក្រោយទៅហ៊ីមីនេះហិមានកំនើតដោយសារសំណល់អញសល់ទេ អត់យក គេថាញ៉ុមឆោតគ្រប់គ្នាហា!!

ក៖ ចាំ!!

ខ៖
ញ៉ុមបានប្តីហ្នឹងគ្រាន់បើមែនទែនណាស់ផ្ទះញ៉ុមស្លឹកជញ្ជាំងកក់តែលុយញ៉ុមអត់ខ្វះអ្នកណាយកលុយរាប់រាប់ទៅ!!

កៈ ហ៊ឺៗ!!

ខៈ តែវាមាចាញ់បោកគេមួយចំនុច។

កៈ ម៉េចវិញអ៊ំ?

ខៈ  ហើយដល់ពេលអាប្តីមានស្រីអញ្ចឹងខ្ញុំរល់ចិត្តញ៉ុមលែងធ្វើអីចេញ។

កៈ ហ្នឹងហើយអ៊ំអើយធម្មតាអ៊ំអើយមានកូ៣ ៤ហើយ ហើយទៅអញ្ចឹង!!

ខៈ កូននៅលើយើងទាំងអស់។

កៈ ចាំ!!

ខៈ មុនដំបូង!!

កៈ ហើយគាត់ទៅធ្វើបាបគេ!!!

ខៈ  គេទាមទារកូនទាំងអស់ណាស់កូនណាស់។

កៈ ហ៊ឺៗ!!

ខៈ ទាមទារកូនទាំងអស់ញ៉ុមថាយកទៅចុះយកទាំងអាកូនប្តីញ៉ុមមុនទៀតណាស់!!

កៈ ហ៊ឺ!!

ខៈ ញ៉ុមថាអោយកូនស្រីមួយ ចុះកូន៣
៤កូនស្រី១អាណាគេមិនស្រលាញ់យើងស្រលាញ់ដូចតែគ្នាហ្នឹង!!

កៈ ចាំ!!!យកចុះញ៉ុមដឹងមើលយកចុះ បើអ្នកឯងយកកូនទាំងអស់
ហើយយកប្រពន្ធកើតអញអោយពុះអញជា៣ចំរៀកហ្នំក្បាលញ៉ុមអត់មាត់ទេញ៉ុមគិតក្នុងចិត្តញ៉ុម។

កៈ ហើយគាត់ម៉េចក៏ដាច់ចិត្តទៅមានប្រពន្ធ?

ខៈ  ទារយកកូនទាំងអស់ដើម្បីអោយញ៉ុមមិនដាច់ចិត្តអោយញ៉ុមមូលគាត់វិញ!!

កៈ ហ្ហ៎!!

ខៈ ចំនុចហ្នឹងគាត់ ហ៊ីគាត់!!

កៈ គាត់មិនដាច់ចិត្តដែរអ៊ំហោ?

ខៈ ហ៊ីខ្ញុំយកយកទៅ ខ្ញុំអោយ។

កៈ ហើយចុះពេលហ្នឹងមិនព្រមមូលវិញបើគាត់កែប្រែហ្ហ៎!!!

ខៈ ហ៊ី!!!!!

កៈ អត់កែម៉ងអ៊ំហោ?

ខៈ  អូន!! គេថាក្របីក្តៅដេកភក់មិនយូរមិនឆាប់ក្តៅក្នុងចុះទៀតទេ
!!ក្របីចាញ់ក្តៅហា៎អូនឯងចាំអញ្ចឹងទៅ!!ហ្នឹងហើយដល់ពេលនេះទៅញ៉ុមក៏យកកូនមក
គេខាងណោះគេថាគេមេម៉ាយកូនមួយដែរ!!

កៈ ចា៎!!

ខៈ ញ៉ុមមានកូនដែរបើស្រលាញ់ញ៉ុមមានកូនជាប់ខ្លួនអត់យកគេគិតកូន!!

កៈ ចា៎!!

ខៈ ចុះបើកូនញ៉ុមអានេះតាមឪគេ
ទៅតាមឪគេអញ្ចឹងទៅគេទិញមងអោយដាក់កាលហ្នឹងជំនាន់ទូកត្នោតទេណាស់
អត់មានទូកឈើរកទេណាស់។

កៈ ចា៎!!

ខៈ ដល់នេះគ្នាក្មេងសមអីគ្នាប៉ុនដេកទៅជំទៀលហៅ
ជេរគ្នាអាត្រូវគ្រាប់អាជាប់ច្រវាក់លិចទូកងាប់ហើយទេមិនដឹងធ្វើរឹងហើយមិនទាន់មកនៅគេមិ
នបានយកខោអាវមកអត់ហ៊ានចូលផ្ទះទេពាក់ខោអាវនៅហ្នឹងខ្វម មុនញ៉ុមកំសត់ណាស់
ញ៉ុមនៅខ្វមចាំដីគេនោះទេ !!

ក៖ ចាំ!!

ខ៖ ញ៉ុមចុះមានណានេះផ្ទះនេះកូនញ៉ុមអង្វរហៅញ៉ុមមកទេណាស់ឆ្លងទន្លេកូននេះ
វាចាប់ទម្ងន់កូននេះវាអត់និយាយរកខ្ញុំសោះញ៉ុមអត់មានរឿងអីជាមួយវាទេណាស់ញ៉ុមនៅល
ក់ឥវ៉ាន់នៅណោះទេណាស់ ញ៉ុមឆ្ងល់កូនប្រសារញ៉ុមហាំអត់និយាយរកយើងទេ
យើងមកលេងអីចឹងញាតិគេថាហ្វាំមកបានប៉ុន្មានថ្ងៃហើយ
វានៅអង្គុយចិតបន្លែវាធ្វើមិនមើលយើងទេណាស់។

ក៖ ចឹបានអីចឹងកូនប្រសារ?

ខ៖ អីចឹងបានឆ្ងល់ហាំវាឆ្ងល់ខ្លួនវាដែរតើ!!ទម្ងន់កូនហ្នឹងដូចថាវាស្អប់យើងតែម្តងហាំ!

ក៖ ហ៊ី!!

ខ៖ ដល់នេះគេក៏ឆ្លងទន្លេគេនិយាយថា ណោះអាទៅហើយមិនទៅអាមិនទៅល្អជាង។

ក៖ ហ៊ី!!

ខ៖ គេនិយាយអីចឹងហាំ កូនញ៉ុមអត់ហៅញ៉ុមទៅទេ ពេលវាវះ
ទាំង២ហ្នឹងវះតើ(កូនទាំងពីររបស់កូនប្រុសគាត់) ញ៉ុមអត់ទៅទេ ដល់នេះគេចេញហើយ
ដល់ថ្ងៃចេញកូនប្រុសញ៉ុមអាប្រុសហ្នឹងគេតែមក ម៉ែម៉ែឯងរកកំបោរសរពទ្ធ័សីមាអោយខ្ញុំផង
អញមិនដឹងទៅរកឯណាទេកំបោរសរដល់តែហ្អែងដុតលៀសខ្លួនឯង។

ក៖ ហ៊ី!!!

ខ៖ ញ៉ុមចងចាំពាក្យអាគេថាហ៊ីមិនខ្វល់ទេ អោយតែប្តីប្រពន្ធញ៉ុមស្រលាញ់គ្នា
ម៉ាតែម៉ែឪញ៉ុមមិនខ្វល់ទេ!!

ក៖ ហ៊ី!!

ខ៖ ដល់តែពេលគេមកបាននិយាយបានថាគេមកគេអោយញ៉ុម១០០០អីចឹងបានញ៉ុមថាមិនរក
គេមកមិនដឹងបានកំបោរសរពីណាពទ្ធ័សីមាញ៉ុមឃើញជិះកង់បី បីកូនដាក់ក្នុងផ្ទះប៊ិប
ញាតិគ្រប់គ្នាថាពងមាន់កំចង់ជល់នឹងថ្ម!!

កៈ ហ៊ឺ!!

ខៈ ថាអញ្ចឹងណាស់!!

កៈ ដល់ពេលឥឡូវនិយាយជាមួយអ៊ំហើយហោ?

ខៈ  និយាយហៅញ៉ុមមកទេនេះ អង្វរញ៉ុមទេបានញ៉ុមមកនៅហាំ!!កូន!!

កៈ ហ៊ឺ!!

ខៈ
កូនហ្អែងកុំឃើញថាផ្ទះខាងណោះគេអត់អោយអញនៅអត់មានផ្ទះជ្រកហាំតិចថាម៉ែដើរសុំទានគេអញអត់សុំដាច់ខាត។

កៈ ហ៊ឺ!!

ខៈ មុខរបរអញមានអញដើររើសតែកំប៉ុងលក់ក៏អញចិញ្ចឹមខ្លួនអញរស់ដែរ។

កៈ ចាំ!!

ខៈ ហើយញ៉ុមអានិតតែកូនបង ម៉ែម៉ែឯងមកណេះមក
កូនអើយកូនឯងហ្លួបតែមាត់មិនគ្រប់អោយយកម៉ែទៅទៅជួលផ្ទះហ្អែងមានលុយប៉ុន្មានកម្មករគេសោះហ្នឹងម៉ែអត់ទៅទេបើទៅលេងម៉ែទៅ។

កៈ ចុះកូនស្រីអ៊ំ?

ខៈ  កូនស្រីញ៉ុមមានប្តីតែដូចម៉េចទេ ដូចអត់សូវយកចិត្តទុកដាក់យើង។

កៈ អត់សូវយកចិត្តទុកដាក់ជាមួយម៉ែហោ?

ខៈ  ហ្នឹងហើយនោះផ្ទះជិតគ្នាដែរ ហើយដល់ពេលនេះទៅកូនញ៉ូមមីស្រីគេរក
កូនប្រសារហាម៉ែអើយម៉ែឯងមកនៅមក
ម៉ែឯងទៅនៅឯណាមុនដំបូងញ៉ុមធ្វើតេទៅថាបុលហាអញសុំមកនៅអាផ្ទះក្រោមដើមព្រីងនោះសិនហាម៉ែហ្អែងអត់នៅដដែលណាស់ម៉ែឯងនៅហ្នឹងហ៊ានទេ

?ហ៊ឺអញខ្លាចអីស្រុកកំណើតអញអញមានពេជ្រណាអោយគេមកប្លន់ហាំ!!ផ្ទះអាជីមុខហ្នឹងគេអោយគេចាំតើ!!

ក៖ ចាំ!!

ខ៖ ចាំដល់តែនេះទៅកូនស្រីតេហៅម៉ែម៉ែឯងមកមើលមុខចៅហិ!!

ក៖ ចាំ!!

ខ៖ អើយសុខសប្បាយសុខសប្បាយទៅកូនអើយគ្មានសំខាន់អី
ម៉ែវាមិនសំខាន់ដូចប្ដីប្រពន្ធខ្លួនឯងទេ!!

ក៖ ហ៊ឺ!!

ខ៖ ញ៉ុមដាក់មួយម៉ាត់ហ្នឹងទៅ!!

ក៖ ពេលមុនអោយតែប្ដីប្រពន្ធស្រលាញ់គ្នាមិនខ្វល់ម៉ែឪទេណោះ?

ខ៖ គេនិយាយប្រាប់កូនប្រសារញ៉ុមប្រពន្ធអាពៅហ្នំ!!

ក៖ ហ៊ឺ!!!!

ខ៖ បងគឺមគាត់និយាយថា គាត់មិនខ្វល់ទេម៉ែអោយតែ
អើរស៊ីសងតែប្ដីប្រពន្ធគេស្រលាញ់គ្នាហើយពេលឆ្លងទន្លេវះហ្នឹងអាយើងទៅមិនទៅ
មិនទៅល្អជាងអូនឯងយល់អត់?គេមិនចង់អោយយើងទៅទេ!!

ក៖ ចាំហ្នឹងហើយ ហ្នឹងហើយ!!មិនទៅល្អជាង!!

ខ៖  ខ្ញុំអត់ចេះអក្សរទេ។

ក៖ ចាំហ្នឹងហើយ!!

ខ៖ ប៉ុន្តែខួរក្បាលញ៉ុមឆ្លាត!!

ក៖ ទៅមិនទៅ មិនទៅល្អជាង។

ខ៖ ហ្នឹងហើយ គេមិនចង់អោយយើងទៅឃើញមុខ អញ្ចឹងយើងមិនទៅ ដល់ហើយអោយមកពទ្ធ័សីមាគេចូលផ្ទះញុំមអត់មក គេរកញុំមតេហៅញុំមមក!!ញុំមថាមកហើយសុខសប្បាយហើយអោយសុខទៅ វាសំខាន់អីជាមួយម៉ែទេសំខាន់អោយតែកូនហើយប្ដីបានសុខ បានសុខហើយ។

ក៖ ចាំ!!

ខ៖ ថាតាមគេថាមកវិញ!!

ក៖  ថាមកវិញទៅ។

ខ៖ មានអីអង្វរ ម៉ែមកនៅឈប់ទៅណាពាក់កណ្ដាលជីវិតហើយ!!

ក៖ ហ៊ឺៗ!!

ខ៖ ញុំមថាម៉ែហាំអត់ចូលចិត្តមនុស្សណាមាត់ផ្សេងចិត្តផ្សេងទេ មាត់ថាបានតែចិត្តមិនដូចមាត់!!

ក៖ ចាំ!!

ខ៖ អញ្ចឹងបានគេថាចិត្តផ្សេងមាត់វាផ្សេងញុំមអត់ចូលចិត្តទេ!!រាល់ថ្ងៃពីមុននៅហា កាលពីញុំមនៅដំបូង ញុំមមកនៅម្ដងហើយញុំមចុះទៅណោះវិញហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ ញុំមអត់ចូលចិត្តទេអាមកគេនិយាយរកបងប្អូនយើងយើងណេះ សូម្បីតែឈ្នួលគេនិយាយថាប្រើនេះប្រើនោះដែរអត់និយាយរកយើងសោះ។

ក៖ អញ្ចឹងដល់ឥឡូវនិយាយរកហើយហោ?

ខ៖  ឥឡូវអត់អីទេ អង្វរញុំមទាល់តែចុះខសន្យាជាមួយញុំមគ្រប់បែបយ៉ាងហ្នំ!!

ក៖ ចាំបានមកជួយមកមើលផ្ទះមើលអីអោយោអញ្ចឹងទៅ?

ខ៖ ហ្នំញុំមមិនមើលបានស្អាតឥឡូវហើយ។

កៈ ហ្នឹងហើយ !!ហើយប៉ុន្មានថ្ងៃបានពួកគាត់មកផ្ទះម្ដងអ៊ំ?

ខៈ រាល់ដងធ្លាប់មកថ្ងៃល្ងាចថ្ងៃសៅរ៍មក ទឹមទៅទេណាស់
ទឹមទៅបែបចាំអាទិត្យក្រោយអីណោះទាល់តែវ៉ាកងហើយបានមក!!

កៈ ទៅធ្វើអីគេវិញនៅណោះ?

ខៈ ម៉ែក្មេកគេម្ចាស់សាលាជ័យថាវីកូនឯងហាំ!!

កៈ ហ្ហ៎ រកបានណាស់អ៊ំណាស់!!

ខៈ ទារលុយសិស្ស!វាស៊ីប្រាក់ខែដែរហ្នឹង!!

កៈ ចាំ!!

ខៈ ហ្នឹងហើយ តែគ្នាកូនខ្ទី គ្នាកូនខ្ទីទៅហ្នឹងវាគ្រាន់តែថាបានដាំបាយអោយប្ដី
ប្ដីរៀបម៉ូតូអោយសិស្សហាំ!!

កៈ ចាំ!!

ខៈ ហើយគេ!!

កៈ អូ្វយរកលុយបានណាស់អ៊ំណាស់!!

ខៈ
ប្រពន្ធវាហ្នឹងទារលុយសិស្សហាំ!!គេដាក់បន្ទប់អោយទារហើយសាលាហ្នឹងសាលាម៉ែក្មេកវា!!

កៈ ចាំ!!

ខៈ ហ្នឹងហើយសាលាម៉ែក្មេកកូនញ៉ុមហ្នឹងហាំ!!ហើយគាត់ប្រាប់ដែរ
ប្រាប់ថាបងអើយបងឯងនៅទៅកុំប្រកាន់វា វាមាត់តែអញ្ជឹងទេ!!

កៈ ហ្ហ៎អញ្ជឹងទៀត!!

ខៈ គាត់ គាត់ដឹងចិត្ត។

កៈ ចាំ អញ្ចឹងគាត់ចេះតែនិយាយប្រាប់អញ្ចឹងទៅ!!

ខៈ អើរគ្នាតែអញ្ចឹងទេ!!

កៈ ចាំ!!

ខៈ ឥឡូវគាត់ទៅថៃបាត់ហើយហាទៅអាមេរិចហាទៅថៃ។

កៈ ចាំ!!

ខៈ ទៅថៃបាត់ហើយ។

កៈ ចាំអញ្ចឹងអ៊ំចូលដល់ជំនាន់ប៉ុល ពតម្តង ដោយសារអ៊ំកើត១៩៥០ដែលរៀងយូរបន្តិច!!

ខៈ ហ្នឹងហើយ។

កៈ តែអត់អីទេ
ដែលកូនចៅនឹងស្តាប់ប្រវត្តិអ៊ំទៅថ្ងៃក្រោយចំនាយពេលតែបន្តិចអត់អីទេអ៊ំណោះ?

ខៈ ចាំចាំ!!

កៈ
ឥឡូវចូលដល់ជំនាន់សង្គ្រាមវិញពេលមុនអ៊ំកើត១៩៥០ពេលហ្នឹងអ៊ំធ្លាប់ឮចាស់ៗនិយាយពីជំនាន់ឥស្សរនឹងបារាំងអីអត់អ៊ំ?

ខៈ  ញ៉ុមឥស្សរបារាំងញ៉ូមអត់ទាន់ទេ។

កៈ តែគ្រាន់តែឮអីអត់អ៊ំ?

ខៈ  មកសម័យលន់ នល់ហាំ!!

កៈ ឥឡូវនិយាយសម័យលន់ នល់ម៉ងទៅបើណោះអត់ទាន់ផងហ្នឹង!!

ខៈ  បើលន់ នល់អាចខ្ញុំដឹងពីសង្គ្រាមម៉ង!!

កៈ ចាំពេលហ្នឹងអ៊ំកំពុងពេញវ័យ២០ជាងហើយអ៊ំណោះ?

ខ៖ ហ្នឹងហើយ មុនលន់នល់ខ្ញុំអត់ទាន់មានគ្រួសារទេ។

ក៖ ចាំ!!

ខ៖ ព្រោះអីបងប្រុសញ៉ុមធ្វើទាហាន!!

ក៖ ហ៊ី!!

ខ៖ បងប្រុសញ៉ុមថាស្លាប់ថាអាយុច្រើនជាងគេហ្នឹង!!

ក៖ ចាំ!!

ខ៖ ហ្នឹងហើយគាត់បងទី១ គាត់ធ្វើទាហាននេះនៅវត្តតាំងក្រសាំងនេះ
គេអោយឈរជើងនៅហ្នឹង!! អើរកាលហ្នឹងគាត់នៅមេទ័ពគាត់ឈ្មោះអើរថាច់
ប៉ូចហាំ!!កន្សែងសរហាំ!!

ក៖ហ៊ីៗ!!

ខ៖ ហើយបងថ្លៃញ៉ុមគាត់ពោះធំហើយគាត់អោយញ៉ុមទៅបើកលុយអោយប្រពន្ធនោះ
ហើយបងញ៉ុមពោះធំចង់ជិតគ្រប់ខែហើយនោះអត់ហ៊ានទេ
ញ៉ុមទៅទួលក្រសាំងនោះមានអីទៅ
យើងទៅល្ងាចហើយយើងមិននៅដេកមួយយប់ព្រឹកឡើងគេមិនបើកលុយទៅបើកលុយអោយ
បងថ្លៃ!!មានណាគ្រាន់តែនេះលែងគ្រាប់មកម៉ង
គ្រាប់ច្រូចៗៗៗគេមានត្រង់សេលាន់ហើយញ៉ុមថាបងឯងអត់ជីកត្រង់សេ
ដល់ហើយបងញ៉ុមថាហុចកថាអោយញ៉ុមបៀមទៅក្រាបតែនឹងភ្លឺស្រែ
អូនអើយគ្រាប់មកឆាំងឆាំង!!ជុំវិញយើង!!

ក៖ អោយកថាបៀមវិញអោយការពារខ្លួន!!

ខ៖ ហ្នឹងហើយ គាត់អោយកថាញ៉ុមបៀមហាំ!!

ក៖ ចាំ!

ខ៖ ហើយគាត់កាន់តែព្រះតែមួយព្រះអង្គហ្នឹងកែលឡើងរប៉ាយ!!

ក៖ ទំលាក់ម៉ងអ៊ំណោះ?

ខ៖ គ្រាប់ជុំវិញញ៉ុមហាំ!!ញ៉ុមសរសើរម៉ងហាំ!!

ក៖ កថាខ្លាំងអ៊ំហេ?

ខ៖ ញ៉ុមក្រាបអញ្ចឹងរហូតគេថាអូរពីរនាក់បងប្អូនម៉េចហើយ
មានអីដល់នេះញ៉ុមថាញ៉ុមអត់អិផង ដល់ហើយញ៉ុមបើលុយឡើងរហ័សមក
ហើយពេលជំនាននន់លន់ នល់ហ្នឹងញ៉ុមក៏វាមានអីអោយនេះដៃរញ៉ុមទៅ
ញ៉ុមទៅមួយគ្រាមួយគ្រាដោយសារញ៉ុមទៅយកលុយអោយបងថ្លៃទេញ៉ុមមិនដែលទៅឆ្លងកា
ត់ទេ តែគ្រាន់តែថាយើងវារត់លួនអញ្ចឹងដែរ !!

ក៖ ចាំ!!

ខ៖ អារឿងសង្គ្រាមហ្នឹងនោះ!!

ក៖ ចាំហើយអញ្ចឹងពេលលន់នល់ហ្នឹងវិញអ៊ំនៅណាវិញផ្ទះ?នៅនេះដដែលហេ?

ខ៖ ញ៉ុមនៅហ្នឹង។

ក៖ តែនៅនេះអត់មានម្លោងអីទេអ៊ំហេ?

ខ៖ កាលញ៉ុមផ្លោង ផ្លោងតែទួលក្រសាំងពោធិ៍ចិនតុងអីណោះហ្នឹង
ញ៉ុមទៅយកលុយនៅហ្នឹង!!

ក៖ នៅនេះអត់ផងហេ?

ខ៖ នៅនេះអត់អីវិញទេ។

ក៖ ហ្វាំ!!

ខ៖ ចាំ ហើយបើថាវាឆ្លងកាត់ប៉ុល ពតអាហ្នឹងដឹងថាវាឆ្លងពិបាកមែនប៉ុន្តែអារម្មណ៍យើង!!!

ក៖ ឥឡូវអ៊ំឈប់លន់ នល់សិន!!ឥឡូវអ៊ំមានឃើញសាកសពអីត្រូវខ្មោចខ្មីអីអត់អ៊ំ?

ខ៖
សាកសពចេះតែមានហើយប៉ុន្តែគ្រាន់តែថាឃើញសាកសពពួកទ័ពយើងហ្នឹងឃើញឡើងគរគារឃើញមកអាតាមផ្លូវយើងមកនេះ!!

ក៖ ឃើញលើកដាក់ឡានមកម៉ងអ៊ំហេ?

ខ៖  ហ៊ឺអូន រ៉ុកគ្រោះហា៎ អូនឯងដឹងរ៉ុកគ្រោះអាផ្លូវយើងទៅត្រាំខ្នារទេ!!

ក៖ ចា៎!!

ខ៖ ហួសពីត្បូងត្រាំខ្នារតិចទៅគេហៅត្រាំខ្នារហើស្អីមិនដឹងទេ ពើងហា៎ ពើងដាច់ត្រឹមហ្នឹងហិប្តីមីចន្ទ្រាលោកអើយស្រាប់តែថាក្បាលដាច់បាត់ហើយហ្នឹង!!

ក៖ ហ៊ឺៗ!!

ខ៖ ហើយដឹងទេជំនាន់ហ្នឹង អាពតវាលុកចូលខ្លះហើយណាស់!!

ក៖ ហ្នឹងហើយ ហ្នឹងហើយ!!ដោយសារពេលហ្នឹង!!

ខ៖ អ្នកស្រុកត្រូវជើងខាងណេះផងខាងណោះផង។

ក៖ ចា៎!!

ខ៖ ខាងណោះគេវេចអន្សមអោយពួកអាពតនោះស្ងោរ អាខ្លះស្ងោរបានទៅអាខ្លះអត់ស្ងោរទៅអាពួករ៉ុកគ្រោះអាពួកគេហៅអី ហានុមានគប់លំពែងនោះ។

ក៖ ហ៊ឺ!!

ខ៖ នៅហ្នឹងឈរផាច់ផុកៗឈរនៅទួលកីយើងនេះ។

ក៖ ចា៎!!!

ខ៖ គេឡើងទៅតាកែវផ្លូវយើងទៅត្រាំខ្នារយើងហ្នឹង!!

ក៖ ចា៎!!

ខ៖ គេថាវាមកបុកនៅហ្នឹងខ្លាំងណាស់
យកអន្សមអត់ទាន់ស្ងោរហើយទាំងកញ្ជើរហ្នំ!!!ព្រោះពេលហ្នឹងវាបាញ់គ្នាព្រាវៗ។

ក៖ អ៊ីចឹងពេលហ្នឹងទ័ពលន់ នល់ហើយនឹងទ័ពប៉ុល ពតបាញ់គ្នាចំរ៉ូងចំរ៉ាស់ណាស់ណោះអ៊ំ?

ខ៖
បាញ់គ្នាសាហាវណាស់!!ហើយញ៉ុមកាលហ្នឹងមានបងប្អូនទៅម្ល៉េះហើយគេធ្វើបន្ទាយនៅទួលកីហ្នឹងញ៉ុមមិនថាទៅ ដល់នេះញ៉ុមមានស្អីៗហ្នឹង ញ៉ុមមិនទៅយកស្អីអោយបងស៊ី
ដល់យកទៅហ្នឹងទទួលគេទឹមតែរៀបរ៉ុកគ្រោះ ទៅណាទៀតហើយទេ
គេឡើងទៅផ្លូវតាកែវទៀតហើយថាមកហ្នឹងឡើងកកកុញហ្នំ!!ថាសមអ្នកស្រុកហ្នឹងត្រូវដៃត្រូវជើងទៀត
ត្រូវដៃជើងខាងហ្នឹងហើយដល់ពេលដែលពួកយើងទៅវាអោយមកហាំថាអញ្ចឹងរហូតថាហ៊ុលន់ នល់មកអញ្ចេះៗមក
ទំរាំតែបានឈ្នះវាហ្នឹងឈ្នះវាបានតែមួយគ្រាហ្នឹងស្រាប់តែវារហូតអានៅមុខវត្តស្ទឹងមានជ័យនេះ!!

ក៖ ហ៊ឺ!!

ខ៖ វាមកតាមផ្លូវអញ្ចឹងមក។

ក៖ អ៊ំពេលហ្នឹងប៉ុល ពតអីវ៉ាន់ក៏ពេលហ្នឹងខ្មែរក្រហមមកកើតមកពីណាវិញ?

ខ៖  ខ្មែរក្រហមមានពីណាមានតែខ្មែរយើងហ្នឹង។

ក៖ ចាំ!!

ខ៖ តែដឹងទេថាវាមានដូច២បក្សអ៊ីចឹងទៅណាស់!!

ក៖ មួយកាន់ជើងខាងស្ដេចមួយកាន់ជើងខាងលន់ នល់?

ខ៖  លន់ នល់ ហ្នឹងហើយ!!

ក៖ តែពេលហ្នឹងដូចលន់ នល់ មានអំណាចជាងអ៊ំណោះ?

ខ៖ ត្រូវហើយលន់ នល់មានអំណាចជាង!!

ក៖ តែអំពេលហ្នឹងលន់ នល់ ជាមនុស្សល្អអត់?

ខ៖ ញ៉ុម!!

ក៖ បើតាមអំលឺពីជំនាន់ពីមុនៗមកហាំ?

ខ៖ លន់ នល់កាលហ្នឹងហាំ
គាត់ការពារអាពតខ្មែរក្រហមមិនអោយមកចូលធ្វើបាបប្រជារាស្ត្រយើងទេណាស់។

ក៖ ចាំ!!

ខ៖ ប៉ុន្តែមានរនុកក្នុងកូនឯងដឹងទេ?

ក៖ ហ៊ឺ!!

ខ៖ តែមានរនុកក្នុងអត់បានក្តីសុខទេ។

ក៖ ហ្នឹងហើយ វាមាន វាដឹងអានេះទៅប្រាប់អានោះ។

ខ៖ ហ្នឹងហើយ!!

ក៖ ហ្នឹងហើយ!!

ខ៖ វាយកការពីយើងទៅអោយអានោះ។

ក៖ ចាំ!!

ខ៖ យកការពីយើង មកអោយ វាអោយយើងទុកចិត្តចេះតែធ្វើថាអញ្ចឹងទៅណាស់។

ក៖ ហើយអំ!!

ខ៖ តែវាយកខាងយើងទៅអោយខាងណោះខ្លាំងជាងហើយ!!

ក៖ តែពេលហ្នឹង!!

ខ៖ វាចង់មានបុណ្យសក្តិនោះ។

ក៖ ចាំ
អ៊ំញ៉ុមលឺគេនិយាយហាថាអើរពេលហ្នឹងវៀតណាមនៅក្នុងស្រុកខ្មែរយើងហេហើយថាសម្លាប់លន់ នល់ សម្លាប់តាមបណ្តែតទឹកទៅហ្នូ!!

ខ៖ កាលហ្នឹងហាំគេហៅថាអាយួនធ្មេញខ្មៅ!!

ក៖ ហ៊ឺៗ!!

ខ៖ ញ៉ុមឯណេះគេហៅថាបារ៉ែនមានជោគមានជ័យហ្នឹងហើយញ៉ុមទៅហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ វាធ្មេញខ្មៅដូចស៊ីស្លាអញ្ចឹង។

ក៖ យួនហ្នឹងហេ?

ខ៖  យួនហ្នឹង!!

ក៖ ចាំ!!

ខ៖ យួនវៃ!!យួនជើងយួនត្បូងហាំ!!

ក៖ ចាំ!!

ខ៖ សាហាវណាស់យួនហ្នឹងហាំ!!

ក៖ ចាំអញ្ចឹងពេលហ្នឹងនៅក្នុងលន់ នល់នៅឡើយទេ?

ខ៖  នៅក្នុងលន់ នល់តើ!!

ក៖ ហើយម៉េចពេលហ្នឹងគាត់ទៅសម្លាប់បណ្តែតទឹកទៅវិញ?

ខ៖  បណ្តែតទឹកទៅវិញចុះអាពតវាចូលមកហើយ។

ក៖ ហ្នំ!

ខ៖ អាពតចូលមកបានចងជើងចងដៃបណ្តែតទៅអាខ្លះទាហានប៉ាវ៉ាទៅ
អាខ្លះទាហានយើងទាហានធម្មតាហ្នឹង!!

ក៖ ចាំតែពេលហ្នឹងមានទ័ពរបស់យួនមកដែរតើអ៊ំហោ?ពេលក្នុងលន់ នល់ហាំ??

ខ៖ យួនហ្នឹង ទ័ពយួនវាមកជួយហាំ!!

ក៖ អាហ្នឹងពេលហ្នឹងពេលនៅប៉ុល ពតទេ!!ជួយ!!

ខ៖ អត់ អត់ទេអាកាលអាយួនហ្នឹងចូលមក វាចូលមកវាយកលេសទេ!!

ក៖ ជាមួយខ្មែរក្រហម។

ខ៖ វាចូល ចូលយកលេសទេ យកការពីយើងនេះ!!

ក៖ ហ្អាំកាលហ្នឹងកាលពេលនៅលន់ នល់ ក៏មានទ័ពយួនដែរ?

ខ៖ ខ្មែរក្រហមហាំញ៉ុមទៅដល់អាកន្លែងគេហៅអាកន្លែងបានជោគបានជ័យហាំ
ទៅដល់ភ្លាមដឹងថាទ័ពខ្មែរទៅដល់ភ្លាមផ្ទះមានអត់មានមនុស្សប្រុសទេ!!

ក៖ ហ៊ឺ ចាប់អស់រលីងហើយអ៊ំណេះ?

ខ៖ មនុស្សប្រុសវាទៅចូលក្នុងព្រៃហាំចាំយកការពីទាហានលន់ នល់ហ្នឹងហិ!

ក៖ ហ៊ឺ!!

ខ៖ គ្រាន់តែទៅដល់ព្រៃព្រឹបសុវណ្ណធីណៃមកដល់ព្រោកឆឹង ព្រោកឆឹងហ្នឹង!!

ក៖ ហ៊ឺ!!អ៊ំពេលហ្នឹងដូចមានរឿងរញ៉េរញ៉ៃច្រើនណាស់អ៊ំហោ?

ខ៖ ចាំរញ៉េរញ៉ៃ។

ក៖ ឥឡូវអ៊ំប្រាប់សិន វែកញែកសិនមើល!!នៅក្នុងទ័ពលន់ នល់មានទព័មានទ័ពលន់
នល់មួយ!!

ខ៖ លន់ នល់មួយ!!

កៈ ទ័ពរបស់ស្តេចសីហនុ២ កន្លែងសរហ្នឹងហោអ៊ំហោ?

ខៈ ហ្នឹងហើយ។

កៈ គេហៅខ្មែរក្រហមហ្នឹងហោ?ហើយគេហៅយួនអោយមកជួយទៀត?

ខៈ ញ៉ុមវាពិបាករឿងកន្លែងហ្នឹងដែរ ពិបាកយល់ដែរ!!

កៈ តែយួនមកជួយខ្មែរក្រហមឬក៏មកជួយលន់ នល់អ៊ំ?

ខៈ ខាងហ្នឹងញ៉ុមដូចអត់យល់។

កៈ អត់យល់ដូចរាងវល់ម៉ងអ៊ំហោ?

ខៈ  ញ៉ុមអត់យល់ទេ ញ៉ុមយល់ ញ៉ុមយល់តែរឿងថាកាលជំនាន់លន់
នល់មានតែទ័ពខ្មែរមួយវ៉ៃយកអាណាអីណីខ្លះទេ
តិចទៅគេថាខ្មែរក្រហមតិចទៅគេថាយួនចូលហើយវាអញ្ជឹង!!ហើយយើងមានទៅចាប់អារម្
ណ៍អីណា។

កៈ ចាំ!!

ខៈ ហើយយើងមានប្តីណាទៅធ្វើទ័ពគ្រាន់តែយើងមានប្តីអោយទៅធ្វើទ័ពហ្នឹងទៅធ្វើទ័ព។

កៈ ស្មគ្រ័ខ្លួនឯងឬក៏ម៉េចអ៊ំ?បងប្រុសរបស់អ៊ំ?

ខៈ  កាលហ្នឹងមិនដឹងគាត់ស្មគ្រ័ចិត្តខ្លួនឯងមិនដឹងចូលទៅក្នុងទាហានលន់ នល់!!

កៈ ហ៊ឺ!!

ខៈ កាលហ្នឹងពួកហ្នឹងពួកកន្លែងសរហាំ!!

កៈ អ៊ីចឹងកន្លែងសររបស់លន់ នល់ទេ?

ខៈ ហ្នឹងហើយខាងកន្លែងសរ។

កៈ ដល់ពេលក្រហមរបស់??

ខ៖  មិនដឹងរបស់អ្នកណាញ៉ុមអត់ដឹតងអត់យល់ដែរកូនឯងមើល កន្លែងសរញ៉ុមអត់យល់ទេ!!

ក៖ ដោយសារច្រើនពេកអ៊ំហោ?

ខ៖ ដោយសារញ៉ុមនៅតូចហា៎!!

ក៖ ហើយអ៊ំហើយពេលហ្នឹងអ៊ំឃើញយួនអីគេបណ្តោតទំលាក់ទឹកទៅមែនហោ?

ខ៖ ខ្ញុំ ញ៉ុមគ្រាន់តែអញ្ចេកកាលមួយហឹកហ្នឹងញ៉ុមចេះតែរត់ដែរគេចេះតែដេញតាមដែរ!!

ក៖ ហ៊ឺ!!

ខ៖ ញ៉ុមទៅច្រកនៅហ្នឹងវត្តទំរាំតែហ្នឹងបានមកចូលមកដល់ភ្នំពេញគេថា
គេថាអើរគេដេញអញ្ចឹងទៅទៅរកកន្លែងជំលៀសខ្លួនអោយផុតផុតទៅណាស់ខ្លាចអាស្អីអាដេ
សេអានោះវាផ្លោងខ្លាំងណាស់។

ក៖ ចា៎!!

ខ៖ ដេសេអាហ្នឹងវាអត់មានដេកាប៉ាអោយយើងដឹងទេណាស់អាគ្រាប់ផ្សេងគូដេប៉ាលីដឹង។

ក៖ ចា៎!!

ខ៖ ហើយមកហើយ!!អានោះមកធ្លាក់មកម៉ង!!

ក៖ មកស្ងាត់ម៉ងហោ?

ខ៖  មកស្ងាត់ ធ្លាក់ផ្ទុះប៊ឹងម៉ង។

ក៖ ចំ!!

ខ៖ បានញ៉ុមច្បាស់ ច្បាស់ហ្នឹង!!

ក៖ គ្រាប់អីគេវិញ?

ខ៖  ដេសេអា។

ក៖ ដេសេអា ៣ម៉ាត់!!

ខ៖  ខ្ញុំ ខ្ញុំច្បាស់
ហ្នឹងដេសេអាហ្នឹងហាំញ៉ុមអត់ដឹងមុនដំបូងកាលហ្នឹងគេដាក់គងអញ្ចឹងហិញ៉ុមច្បាស់ញ៉ូមចេញពីអាពតញ៉ុមច្បាស់ពីអាពតជំលៀសពីអាពតមកហើយទេនេះដេញគេវ៉ៃបានចូលហើយហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ គេមិនដេញអាពតញ៉ុមមិនទៅទើរនៅពោធិ៍សាត់រាល់ខែ។

ក៖ ហ៊ឺ!!

ខ៖ ហើយគេថាហ៊ឺស្រាប់នេះស្រុកដែលគេស៊ីមនុស្សគេមានគោមានក្របីគេទឹមរទេះមកហើយញ៉ុមមានណាប្អូនថ្លៃរយើងរយោងមកហើយកូនញ៉ូមអាបងហ្នឹង៥ខែហ្នឹង។

ក៖ ហើយប្តីស្លាប់ចោលបាត់ហើយ?

ខ៖  ប្តីស្លាប់ចោលបាត់នៅតែប្អូនថ្លៃប្អូនថ្លៃ!!

ក៖ ហើយអ៊ំពេលហ្នឹងស្រណោះប៉ុណ្ណា!!

ខ៖ ហើយប្អូនថ្លៃគេមកស្រុកបាន
គេទៅស្រុកគេកោះធំអស់ទៅហើយញ៉ូមមកស្រុកញ៉ុមណោះហើយវាសួរបងឯងទៅស្រុកញ៉ុមអត់? អញអត់ទៅទេអូន
អញទៅរកបងប្អូនបងដែរអូនឯងទៅចុះបើអូនឯងទៅរកផ្ទះឃើញអោយដំណឹងបងផង!!

ក៖ ហ៊ឺ!!
ត្រលប់មកវិញម៉េចវិញទៅអ៊ំអើយ!!ងើបពីសង្គ្រាមដើរមកវិញស្រណោះស្រណោកម៉េចទៅអ៊ំ?

ខ៖  ណោះខ្ញុំហាំជាប់លេខមួយខាងជិះឡានឈរ។

ក៖ ឈរមករហូត?

ខ៖  ឈររហូតពីពោធិ៍សាត់មក
កូនញ៉ុមឪអានេះរាគរហូតគេផ្លោងចូលសុំត្រង់សេគេច្រកលោកអើយសារ៉ុង៣
៨រាគរហូតទាល់តែជិះឡានហ្នឹងមកឡានហ្នឹងដាក់ចំនុះ៨០នាក់។

ក៖ ហ៊ឺ ហើយឡានប៉ុន្មានទៅអ៊ំ?

ខ៖ ឡានហ្នឹងរបៀបដូចឡានទ្រុងដែរហាំដាក់៨០នាក់
ហើយមុនដំបូងគេដាក់ថាអោយមកដល់ភ្នំពេញគេយកមួយនាក់មួយជី។

ក៖ ហ៊ឺ!!

ខ៖ យកមួយនាក់មួយជី ។

ក៖ ហ៊ឺ!!

ខ៖ ហើយដល់នេះញ៉ុមថាចេះមុនប្តីញ៉ុមមុនស្លាប់ទៅចាប់កូនជ្រូកបានមួយមក
កូនជ្រូកហ្នឹងមាន៥ទៅរកម្ហូបអោយប្រពន្ធ!!

ក៖ ចាំ!!

ខ៖ ហូបថាកាលយើងនៅណោះអត់មានបាយហូបអត់មានអី
ឥឡូវមានបាយហូបអត់ម្ហូបអូនឯងនៅហ្នឹងហើយបងទៅរក !!
ទៅគ្នា៥នាក់ឃើញកូនជ្រុកហ្នឹងបែកពីមេវា៥!!

ក៖ ចាំ!!

ខ៖ ឃើញជ្រូកមេហ្នឹងវាមានកូន៥ ដល់ទៅស្ទាក់អែអាមេជ្រូកគេងាប់
អែអាមេវាងាប់ទៅវះសាច់យកមកហើយញ៉ុមក៏យកមក
ហើយគាត់តថាកុំមាត់អូនឯងកុំហូបអាហ្នឹងណាស់!!

ក៖ ហ៊ឺ!!

ខ៖ គេ គេកាលហ្នឹង គេរត់មាត់ហៅតែមិត្តនារី!!

ក៖ ចាំ!!

ខ៖
មិត្តនារីឯងកុំហួបអាហ្នឹងហាំ!!ថាមិត្តនារីអីទៀតអាពតនៅដល់ណាទៀតហ្នឹង!!ជំនាន់ហ្នឹងអ្នកណាអោយហ៊ានហៅអូនបង!!

ក៖ ចាំ!!

ខ៖ អាជ្រូកនេះជ្រូកមេទេណាស់កុំហួបទាស់។

ក៖ ខ្លាចទាស់អំហេ?

ខ៖ហ្នឹងហើយ ស្រាប់តែយកសាច់មកអោយប្អូនថ្លៃហ្នឹងអាខ្វោកបាញ់ទឹកដោះច្រែកងាប់ហើយហើយជ្រូកហ្នឹងមានកូនហិ មើលទឹកដោះច្រើនណាស់បាន២០ថ្ងៃចុះកូនមិនដល់ផង!!

ក៖ ហ៊ី!!

ខ៖ មានកូនមែនញ៉ុមចាប់បានម្នាក់មួយប៉ុនកណ្តុរប្រែងប៉ុណ្ណឹង!!

ក៖ ហ៊ី!!

ខ៖ គេថាចុះអាប្រែងរត់ពីមុនម៉េចមិនចាប់វាធ្វើផង អាគេមានអង្គុបគេធ្វើដាក់កណ្តុរនោះពួកអ្នកពោធិ៍សាត់នោះ!!!

ក៖ ចាំ!!

ខ៖ ស្រាប់ញ៉ុមធ្វើនៅមុខស្ទឹងពោធិ៍នោះ មានឯណាគេងាប់អស់៣ ៤ហ្នឹង
ញ៉ុមណេះមានកូនខ្ទីនោះ
ញ៉ុមនឹកឃើញថាអញ្ចេកចុះវាបៅមេវាអត់មុតទេហេអឺចឹងហាំ!!នឹកក្នុងចិត្តហាំច្រកទឹកបបរអីអូនអើយ ច្រកទៅឈាមមាត់គ្នាឡើងអញ្ចឹង រុកវាដូចមនុស្សហេ
!ដល់នេះញ៉ុមដាច់ចិត្តអោយវាបៅដោះញ៉ូម។

ក៖ ហ៊ីស អោយជ្រូកបៅដោះ?

ខ៖
ចាំ!!ញុំមចិញ្ចឹមទាល់តែបានធំអីចឹងហិ!!ញុំមបានជ្រូកហ្នឹងមកបានលុយជិះឡាន់មកស្រុក!!ប្រវត្តិញុំមអូនណាស់!!

ក៖ ហើយ!!

ខ៖ ប្អូនថ្លៃញុំម!!

ក៖ ហើយអោយវាបៅដោះបានប៉ុន្មានខែ?

ខ៖  ចាំមើលវាបៅដល់តែពេលវាចេះស៊ីបាយ។

ក៖ ចំ!! ជ្រូកហាំអឹំណាស់!!

ខ៖ ចាំមើល!!

ក៖ មិនមែនមនុស្សណា!!

ខ៖ ដឹងអញ្ចឹងហើយតែកូនញុំមវាទូចកូនប៉ុណ្ណឹងហិបៅ
បៅអោយកូនឯងបៅអោយឆ្អែតហើយហើយបានអោយជ្រូកបៅ
ជ្រូកបៅហើយយកលាងដោះលាងអីយកសាប៊ូយកអីលាងដោះទៅ
បៅទៅរត់ទៅហើយវាដឹងណាស់គ្រាប់ផ្លោងភ្លាមរត់មករកយើងភ្លាម។

ក៖ ហ៊ីជ្រូកហ្នឹងអឹំហេ?

ខ៖ ហើយ
ញីទៀតហាហើយអត់មានគ្រូគ្រៀវទេចិញ្ចឹមឡើងធំបាននេះហ៊ីគេមានលុយវ៉ៃវទេះវ៉ៃវទេះវ៉ៃអីទៅស្រុកយើងប្អូនមួយគំនរ ៣
៤នាក់ហើយកូនមួយទៀតហើយដើរទៅណាពេលណាដល់ស្រុកទេមិនដឹងប៉ុន្មានខែទៅនឹកក្នុងចិត្តអីចឹងដាច់ចិត្តយកអាហ្នឹងទៅលក់។

ក៖ ហ៊ី!!

ខ៖ បាន៥ជីហាគេទិញ គេទិញយកធ្វើមេហាព្រោះជ្រូកវាល្អ
គេកាត់ខ្សែដៃគេមួយដំឡឹងកាត់ពាក់កណ្តាលថ្លឹងអោយយើង
អញ្ចឹងដឹងថាមានលុយជិះឡានទៅស្រុកហើយ
ហើយយើងរៀបចំទៅយើងទូលគ្រែប្រអប់ប្តីញ៉ុមខំយកកន្លែងកុងស៊ីស្រានោះយើងកាលហ្នឹង
នៅពោធិ៍សាត់លោកអើយគ្រែស្អាតៗណាស់សុទ្ធតែពួកអ្នកធំដេកណាស់
ដល់នេះ៥០ខ្ទងគេយកទៅយើងលក់គេអត់ទិញទេតែយើងយកមករួច!!ទុកទៅគេមិនកាប់ចោល!!

ក៖ ហ្នឹងហើយ!!

ខ៖  ប៉ុណ្ណោះបានហើយឡើងឡានយកប្អូនមកស្រាប់តែអាកូននេះឈឺរហូត
គេផ្លោងគ្រាប់ទាំងយប់ទៅសុំត្រង់សេគេចូល កូនហ្នឹងរាគសារ៉ុង៤ ៥ហ្នឹង
ហើយដល់តែរៀបមកគក់សារ៉ុងហ្នឹងស្អាត ទៅហ៊ុំកូនជិតដល់យើងមិនឈរ
ហើយចាមវាមិនអង្គុយអញ្ចឹង ចាមវាប្រចោរញ៉ុមរហូតណាស់អូនអើយ!!

ក៖ ចឹបានប្រចោរវិញ?

ខ៖ កូនយើងអាចម៍ទៅលើក្បាលគេហាំ!!យើងឈរគេអង្គុយ។

ក៖ ហ៊ឺ!!

ខ៖ ហើយកាលនោះអាសារ៉ុងហ្នឹងវាប្រឡាក់អស់ទៅ
ញ៉ុមចាំថាចាំមកដល់ព្រែកព្នៅចាំញ៉ុមគក់ណាស់!!

ក៖ ចាំ!!

ខ៖ ដល់ព្រែកព្នៅគេឈប់ឡាន់អោយយើងដែរតើអូនឯង
រឹងអស់ហើយអាហ្នឹងដល់តែពេលនៅក្រមា
ក្រមាវាទ្រាប់ច្រើនជាន់ដែរវាប្រហោងវាមិនស្រកអាក្មេងវារាគអាចម៍
ដាក់នៅលើស្មាយើងហ្នឹងរហូត ខ្លះគេបោះចោលកូនគេល្អៗណាស់បោះចោលស្រីប្រុស!!

ក៖ បោះចោលកូន?

ខ៖  ចាំ!

ក៖ អាបែកហើយសោះហ្នឹង?

ខ៖  កូនអាយុ៥ឆ្នាំអី៧ឆ្នាំអីអូនអើយមិនដឹងម៉ែឪនៅឯណាទេ!!

ក៖ ហ្វ៎!!

ខ៖ វាមកពីភ្នំ អាម៉ែឪអាពតសម្លាប់ចោលអស់ទៅហ្នឹង!!

ក៖ ហ្នឹងហើយ!!

ខ៖ អូនអើយ ខ្លះវិញគេបោះចោលហើយយើងបីរហូត ញ៉ុមតស៊ូកូនហាំមកកូនវាគយប់ ញ៉ុមលោកអើយចេះតែទ្រាំហើយគក់អាក្រណាត់ហ្នឹងអាទឹកអូរទឹកប្រលាយហ្នឹងអោយតែស្អាតៗទៅដល់តែមកមានអីអង្គុយម៉េចបើឡានចំនុះ៤០នាក់!!

ក៖ ហ៊ីៗ!!

ខ៖ ហើយកូនយើងឈឺវាមិនហប់។

ក៖ ហ៊ី!!

ខ៖ ឈរញ៉ុមរហូត ហើយឡានអត់ដំបូលទៀត។

ក៖
អើយក្តៅងាប់ហើយអ៊ំអើយ!!ហើយទំរាំតែជិះមកដល់មិនមែនតិចម៉ោងណា!!ថាឈរឈរស្រោប់តែព្រុសហើយគេអង្គុយអញ្ចឹង គេប្រចោរយើងដាក់ទំនាយវាល
ញ៉ុមថាអូនអើយអូនឯងជេរម៉េចជេរទៅញ៉ុមមិនចង់អីចឹងទេតែធ្វើម៉េចកូនញ៉ុមវាឈឺ។

ក៖ ចាំ!!

ខ៖ គេអោយញ៉ុមចុះគក់កន្ទបគក់អីទៅ។

ក៖ ហ៊ី!!

ខ៖ ដល់ស្ពានជ្រោយចង្វាដល់កន្លែងគេចុះរឹងជើង អង្គុយក៏មិនចុះ
ឈរក៏មិនកើតហើយជាប់កូនក្រមុំគេ២នាក់មកទៀតណាស់!!

ក៖ ហ៊ឺៗ!!

ខ៖ ឪគេនៅនេះនៅចោមចៅនេះហា។

ក៖ ចាំ!!

ខ៖ វាទៅសមរភូមិដល់វាគេបែកឪពុកមកចាំកូនយូរពេកគេដេញពេកគេមិនមក!!

ក៖ ហ៊ឺៗ!!

ខ៖ ហើយជួបវាវាមកកូនវាស្អាតៗណាស់ឈ្មោះវាពិដោរ ឈ្មោះមីនេះ ដល់នេះគេរកម៉ែគេ
អូនឯងទៅទៅរក ស្គាល់ផ្ទះខ្លួនឯងហើយណាស់ អំអើយ!!វាហៅញ៉ុមតែបងៗទេ នៅអើរអាពត
ញ៉ុមថាទៅទៅ រកម៉ែឪអោយឃើញទៅកូនឯងស្គាល់ផ្ទះហើយ
ដល់មានអីដល់ពេលកើតអាផ្សារតាខ្មៅថ្មីនៅអាមាត់ទន្លេនេះហ្នឹង!!

ក៖ ចាំ!!

ខ៖ វាមករកញ៉ុមទាល់តែឃើញហាំ!!វាថា
ថាបងឯងនៅបឹងត្របែកមករកនៅបឹងត្របែកស្គាល់៥០ខ្នងទេ ថាមានឈ្មោះហ្នឹងទេ
ម៉ែកិនអង្ករ២ ៣បេហ្វាំញ៉ុមយកមក យើងទៅខាងចោមចៅគេយើងខាងហ្នឹងគេធ្វើស្រែតើ។

ក៖
អ៊ីចឹងអ៊ំឥឡូវនិយាយពីធ្លាយមកនិយាយពីរមកបណ្តោយតែអ៊ំអត់ទាន់និយាយពីអាជំនាន់ពេល
ដំបូងពេលជំនាន់ប៉ុល ពតហ្វាំ!វាម៉ែចដែរអ៊ំបានចូលប៉ុល
ពតមកហាំ??អាថ្ងៃដំបូងវាដេញយើងពីណាពីណើមកមកវាជំលៀសទៅណា?

ខ៖ យើងទៅ កាលហ្នឹងគេមិនដេញពួកទាហាន!!

ក៖ ចាំ!!

ខ៖ ដល់តែផ្អើលពួកទាហានមកវាមិនផ្អើលដល់អ្នកស្រុក!!គេថាបាក់មកហើយមកហើយពួកយើងភៀសខ្លួន!!

ក៖ ហ៊ឺ!!

ខ៖ មិននាំគ្នាយកខោអាវរែកពន់រែកពន់មកទៅទៅ។

ក៖ ពេលហ្នឹងអ្នកកន្លែងខ្លះគេដេញចេញមកម៉ងអំហេ ដេញចេញមកពីផ្ទះម៉ងហេ?

ខ៖ បឹមដេញ គេដើរដេញម៉ងហាំ!!

ក៖ ចាំ!!

ខ៖ ណែការនៅអាពត កាលញ៉ុមនៅអាពតក៏គេដេញមកពីសហាករណ៍ដែរណាស់ដេញអោយយើងជំលៀសចេញហាំ!!ព្រោះអីគេថាអាពតមកហើយអាពតមកហើយ។

ក៖ ចាំ»!!

ខ៖ មានអ្នកចេះខ្មែរមានអ្នកអត់ចេះខ្មែរ!!

ក៖ ហ៊ឺ!!

ខ៖ កាលហ្នឹងកំពុងតែចែកបាយគ្នាហ្នំ!!ជំនាន់ប៉ុល ពតហ្នឹងនោះ។

ក៖ ចាំ!!អ៊ីចឹងអំពេលអាថ្ងៃដំបូងនៅស្រុកនៅឡើយទេហេ?

ខ៖ ញ៉ុមនៅស្រុកកាលបែក ហាកាលនេះហ្នឹងញ៉ុមមិននៅស្រុក។

ក៖ លន់ នល់ នៅស្រុកណោះទេ?

ខ៖ នៅស្រុក
នៅស្រុកប៉ុន្តែដល់តែពេលគេផ្អើលគេរ៉ៃគ្នាគេធ្វើទាហានអីនៅនេះនេះនៅទួលគីនេះ!!

ក៖ ចាំ!!

ខ៖ កាលហ្នឹងញ៉ុមនៅផ្ទះនៅទួលគីតើ!!

កៈ ចាំ!!មានបងទៅធ្វើហ្នឹង!!

កៈ ទាហាន!!

ខៈ
ហ្នឹងហើយដល់នេះទៅញ៉ុមចេះតែឡើងចុះកន្លែងបងញ៉ុមទៅព្រោះអីប្រពន្ធគាត់ណោះពោះធំ
កូនខ្ចីឡើងចុះវាពិបាកដល់នេះបងញ៉ុមថា
ណោះប្រាប់គេវ៉ៃគ្នាខ្លាំងណាស់ថាធ្លាយបាក់មកហើយ
ថាប្រាប់បងប្អែងអោយរៀបចំខោអាវទៅ។

កៈ ចាំ!!

ខៈ ហើយចេះទៅចេះតែឡើយទៅទៅ ទៅតាមគេទៅ។

កៈ អញ្ចឹងក៏មានជំនាន់ប៉ុល ពតចូលមកទៅ?

ខៈ  ហ្នឹងហើយ។

កៈ  ហើយអ៊ំជំលៀសទៅពោធិ៍សាត់ទៅ?

ខៈ  ដល់ប៉ុល ពតគេមិនអោយជំលៀស។

កៈ ចាំ!!

ខៈ  មកវិញថាអញ្ចេកអើយទៅខាងត្រាំខ្នារ។

កៈ ទៅត្រាំខ្នារមុនសិន?

ខៈ  ញ៉ុមទៅត្រាំខ្នារសិនតើ!!

កៈ ហ៊ឺ!!

ខៈ បានមកគេយកឡាន យក១០០ឡានមកដឹកយើងទៅអញ្ចេះវិញទៀតហិ!!

កៈ ចំ!!

ខ៖ ញ៉ុមពីរផ្នែកហាំ!!

ក៖ ហ៊ឺ!!

ខ៖ ញ៉ូមទៅដល់ភូមិបារ៉ែនមានជោគមានជ័យហើយហើយជិតដល់វត្តស្អី ក្អែកសរ ក្អែកខ្មៅអីគេនេះ។

ក៖ ចាំ!!

ខ៖
ពេលហ្នឹងហ្ន៎!!ហ៊ឺអញ្ចឹងយកពួកអ្នកជំលៀសពីបារ៉ែនមានជោគមានជ័យគេថាគេអោយទៅបាត់ដំបង ។

ក៖ ហ៊ឺ!!

ខ៖ មានទៅបាត់ដំបងណាគេដឹកទៅសហករណ៍ក្បាលឈើពុកហ្នឹងទៅអញ្ចឹងម៉ងហ្នឹង។

ក៖ ចាំ!!អញ្ចឹងអ៊ំគេថានៅពោធិ៍សាត់ហ្នឹងគេថាសម្លាប់សាហាវណាស់!!

ខ៖ ពោធិ៍សាត់ហ្នឹងសាហាវ ញ៉ុមមិនមែនចូលពោធិ៍សាត់ណា។

ក៖ អ៊ំនៅណាវិញ?

ខ៖ ញ៉ុមហួស។

ក៖ ហួសទៅទៀត?

ខ៖ ២៥គីឡូហួសពោធិ៍សាត់។

ក៖ អញ្ចឹងហោងហើយ!!

ខ៖ ហ្នឹងហើយ ហោងហើយ បានញ៉ុមដាក់ហួសទៅហាំ!!

ក៖ កុំអីនៅពោធិ៍សាត់គេថាសម្លាប់រង្គាលម៉ងអ៊ំ?

ខ៖ ពោធិ៍សាត់គេសម្លាប់ហើយវាថានាយទុនច្រើនណាស់ នៅកកកុញនៅពោធិ៍សាត់។ក៖ ចំ!!ខ៖ សូម្បីតែមួយផ្ទះមួយផ្ទះណាស់ ខាងពោធិ៍សាត់ខាងលៀច។

ក៖ ហ្នឹងហើយគេថាលៀចហ្នឹងគឺថាសាហាវម៉ង!!

ខ៖ លៀចសាហាវម៉ង
វាផ្លោងពីលៀចចូលពោធិ៍សាត់ហ្នឹងហាំញ៉ុមទៅរកគ្រាប់អាកន្លែងហ្នឹងហិវាផ្លោងមកតែម្តង ឃើញវៀតណាម ឃើញវៀតណាមមកស្រាបហាថាអញ្ចេក ទាហានប៉ុល ពត ញ៉ុមមានឮអីឮតែគល់ពោត គល់ពោត គល់ពោតណា ហើយពូសឿនពូសឿនហ្នឹងគាត់ចេះវៀតណាម។

ក៖ ចាំ!!

ខ៖ ហើយគាត់នៅសហករណ៍ញ៉ុម ហើយញ៉ុមណោះកំពុងដួសបាយចែក ចែករបបហ្នំ!!

ក៖ អាហ្នឹងពេលយួនមករំដោះហ្នឹងហោ?

ខ៖ ពេលបែកហើយហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ វាមកហើយ បែក យួនគេមករំដោះបានមួយកាត់មួយកាត់ហើយណាស់!!

ក៖ ញ៉ុមឃើញអាតានោះឡើងត្នោត គាត់យួនមកហើយយួនមកហើយ !! ឯណា ឯណា?? ចែកបាយគ្នាអោយហើយយួនចូលមកហើយ ចែកបាយគ្នារត់ គ្មានដឹងទេ!!

ក៖ កាលពេលហ្នឹងពេលគេមករំដោះអត់ដឹងទេ!!

ខ៖ អត់ដឹងទេ។

ក៖ ដឹងតែខ្លាចតែគេមកធ្វើបាបថែមទៀត!!

ខ៖ ខ្លាចគេថែមទៀត ចែក ចែកទៅ
ហើយខ្ញុំក៏អត់ចាប់អារម្មណ៍មេកងញ៉ុមនេះញ៉ុមឆ្ងល់!!មិត្តនារីហាំ!!ចាំបងនេះយកកូនសោរនេះទុកទៅណាស់ ខ្ញុំទៅ ខ្ញុំគេអោយទៅរៀននៅភ្នំ វាគេចហាំ!!

ក៖ ហ៊ឺ!!

ខ៖ ពួកវាគេចទៅបាត់ហើយអោយ
កូនសោរអាដេញមកទ្រុងទានោះសំរាប់ចាប់ទៅយកពងទាហើយសោរនៅក្នុងនេះគេដាក់អីវ៉ាន់ហូបហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ គេទុកសោរអោយយើងហ្នឹងហិ!!

ក៖ ហ៊ឺ!!

ខ៖ ហើយញ៉ុមឆ្ងល់ព្រោះយើងចុងភៅហ្នឹង ញ៉ុមអត់មាត់ទេ គាត់អត់ប្រាប់ថាគាត់គេចទេ
មេកងមេអីហ្នឹងគេទៅណាបាត់ទៅណោះ!!

ក៖ ហ៊ឺសុទ្ធតែពួកអាពតហ្នឹងអំហេ?

ខ៖  ពួកអាពត!!

ក៖ ហ៊ឺសុទ្ធតែពួកអាសម្លាប់គេហើយហ្នឹងហេ?

ខ៖  ហើយស្រាប់ដល់ពេលហើយស្រាប់ក្រោយមកមានប៉ុល ពតគេសួរ
ថាម៉េច?គល់ពោត!!ប៉ុល ពតហ្នឹងហា និាយយអត់ច្បាស់ដល់នេះ !!

ក៖ ខាងវៀតណាមហ្នឹងនិយាយហ្នឹងហេហើយមានអ្នកបកប្រែ។

ខ៖ ហ្នឹងហើយដល់ពេលពូសឿន
អត់ដឹងពូសឿនចេះវៀតណាមទៀតហ្នឹងហាំ!!និយាយអោយរូ ប៉ុល ពតអត់ស្គាល់!!

ក៖ ហ៊ឺ!!

ខ៖ អត់ស្គាល់ប៉ុលពតម៉េចផងហ្នឹង!!

ក៖ ចាំ!!

ខ៖ ចុះបើសួរអញ្ចឹង ប៉ុល បតហ្នឹងមេហ្នឹង ហើយនៅសហាករណ៍ញ៉ុមហ្នឹងឈ្មោះអ៊ំថាប់ អ៊ំថាប់ហ្នឹងគាត់ប្រើក្តៅតែគាត់អោយហូបខ្លាំង។

ក៖ ហ៊ឺ!!

ខ៖ ត្រីជីកពីទន្លេ គេដឹងយកមកអោយ។

ក៖ អញ្ចឹងអ៊ំពេលនៅប៉ុល ពត ហូបចុកហូបអីហ្នឹងស្រួលអីហ្នឹងគេទេ?

ខ៖  ស្រួលប្រួល ។

ក៖ ដោយសារធ្វើការនៅរោងបាយ។

ខ៖
ហ្នឹងហើយញ៉ុមហូបស្រួលប្រួលប៉ុន្តែអ្នកកាន់នេះហ្នឹងខ្ញុំខាងរោងបាយចាត់ចែងនៅខាងច្រូតស្បៀវ ទៅកុមារ ញ៉ុមអ្នកដាំបបរអោយគេ!!

ក៖ ហ៊ឺ!!ចាំ!!ទៅដាំបបរអោយគេអញ្ចឹងទៅអ៊ំណោះ?

ខ៖ ចាំ!!កងកុមារហាំ ចែកអោយកុមារហូបមុន ហើយក្នុង១០នាក់ មួយកំប៉ុង១០នាក់។

ក៖ កុមារហ្នឹងហោ?

ខ៖  កុមារហ្នឹង ដល់តែមនុស្សចាស់១០នាក់អោយតែអង្ករតែ៦កំប៉ុងអីទេ។

ក៖ ចាំ!!

ខ៖ ហ្នឹងហើយ!!!

ក៖ ហើយអ៊ំគេថាកន្លែងខ្លះបបរមួយខ្ទះគេអោយតែបបរមួយកំប៉ុងទេណាស់(អង្ករមួយកំប៉ុង)!!

ខ៖ ហ៊ឺមួយកំប៉ុងគ្រាន់បើហើយ សហាករណ៍កោះជុំមួយខ្ទះមួយស្លាបព្រាអង្ករ។

ក៖ អាខ្ទះប៉ុននេះហ្នឹងហី?

ខ៖  ចាំ!!វាល់ទឹកហើយហើយសល់!

កៈ និយាយអ៊ំអាណា!!

ខៈ សល់វាល់ស្លាបព្រាចែកទេ វាល់អាគ្រាប់អង្ករហ្នឹង អាស្លាបព្រាហ្នឹងចែកទេ!!

កៈ ហើយអ៊ំអ្នកណាគេអ្នកបញ្ជាមកអោយថាហូបអោយតែប៉ុណ្ណឹង អ៊ំអ្នកដាំបាយហ្នឹងហាតើអ្នកណាជាអ្នកបញ្ជាមកថែម?

ខៈ ថ្នាក់លើហ្នឹងហា៎គេមេធំអាពតហ្នឹងហើយ។

កៈ វាប្រាប់ទៅ?

ខៈ វាថាកុំសម្លាប់គ្រាប់កាំភ្លើងខាត ទុកគ្រាប់កាំភ្លើងបាញ់ខ្មាំង។កៈ ហ៊ី!!ខៈ សម្លាប់តែគ្រាប់បាយបានហើយ។

កៈ អ៊ីចឹងវាប្រាប់មកអ៊ំអីវ៉ាន់អញ្ចឹងទៅ?

ខៈ អត់ប្រាប់ទេ។

កៈ ប្រាប់តៗគ្នាហេ?

ខៈ ប្រាប់ពេលប្រជុំហ្នឹងហា៎!!

កៈ ហ្ន៎!!

ខៈ មេគេប្រជុំប្រាប់តែគ្នាគេអោយដឹងទៅ ម៉្លោះហើយអ្នកមកណោះមកបន្ថយទៅ។

កៈ ហ្ន៎!!

ខៈ ស្រាប់តែ៨០០នាក់អោយអង្ករ៧កំប៉ុង។

កៈ ចំ!!

ខៈ កូនឯងគិតទៅ!!

កៈ មិនដឹងអាណាស៊ីអាណាគេអត់?

ខៈ ៧កំប៉ុងមួយថ្ងៃទេណាស់ ព្រឹក៣ ល្ងាច៣បបរ!!

ក៖ ចំ!!

ខ៖ ហើយកំមែលយកទៅដួសទៅវាល់ទឹកអារឿងកាកទៅ វាល់ស្លាបព្រាចែកទៅ!!

ក៖ ចាំ!!

ខ៖ ចាំ!!

ក៖ ហេមិនដឹងស្អីគេវាទេអំណ្ហើយ!!

ខ៖ គេថាកុំសម្លាប់គ្រាប់កាំភ្លើងសម្លាប់តែគ្រាប់បាយបាននហើយ។

ក៖ និយាយ បើសិនជាពួកវា ពួកវាខ្មែរមែនទេអំ?

ខ៖ ពួកវាខ្មែរ។

ក៖ ហើយចុះបើពួកវាសម្លាប់អស់រលីងទៅបានអ្នកណារស់នៅលើទឹកដីហ្នឹងទៀត!!

ខ៖ ចុះអូនឯងគិតម៉េចម្តាយខ្លួនឯងគេអោយកាត់ករ ហ៊ានកាត់ទៅហើយហ្នឹង។

ក៖ ហ៊ឺ!!

ខ៖ ញុំមខ្លាចកន្លែងហ្នឹងតើ!!

ក៖ វាដើម្បីអីគេទេណោះ ញ៉មឆ្ងល់ដល់ហើយអំ!!

ខ៖ គេថាមិត្តឯងហ៊ានសម្លាប់ម្តាយមិត្តឯង ពីព្រោះអីម្តាយយើងអីមិននៅខាងលន់ នល់។

ក៖ ចាំ!!

ខ៖ អញ្ចឹងបើហ៊ានសម្លាប់ម្តាយកាត់ក្បាលយកទៅអោយគេ គេអោយឡើងបុណ្យសក្តិ
មកដាក់ករម្តាយយ្យូរសក់អញ្ចឹងហ៎!!

ក៖ ហ៊ឺ!!

ខ៖ ៧ជំហានរន្ទះបាញ់ទាំងថ្ងៃត្រង់ហ៎។

កៈ ចំ!!

ខៈ ញ៉ុមជាក់ស្តែងម៉ង។

កៈ អាហ្នឹងសម្លាប់អ្នកមានគុណឯងហាំអឹហាំ!!

ខៈ  ចាំហ្នឹងហើយ ចង់ធ្វើធំហ្នឹងហាអាមនុស្សអត់ចេះអក្សរ។

កៈ ហ្នឹងហើយ!!!

ខៈ អាពតអត់មានអាណាចេះអក្សរទេ!!

កៈ ហ៊ឺ!!

ខៈ អត់ចេះរលីង កុមារហេិប៉ុនចៅញ៉ុមហ្នឹងស្តាយកាំភ្លើងអត់ផុតដីផងហ្នឹង។

កៈ ចាំ!!

ខៈ ស្រាប់តែស្នូងហើយបងផាតហើយយាយប៉ិហ្នឹងគាត់ស្នូង
ហើយដឹបក្សៗកូនឯងឈ្លើងតោងគាត់ស្រាប់តែគាត់ប្រកាច់!!

កៈ ហ៊ឺ!!

ខៈ មិត្តឯងឈ្លើងហើយនឹងគ្រាប់កាំភ្លើងយកអាណា?ញ៉ុមថាយកគ្រាប់កាំភ្លើង!!!

កៈ ខ្លាចឈ្លើងពេកហេ?

ខៈ  ញ៉ុមយកគ្រាប់កាំភ្លើងព្រោះឈ្លើងវាទាមវាក្រងាប់ពេក
យកគ្រាប់កាំភ្លើងមួយគ្រាប់ងាប់ហើយ!!

កៈ ហ៊ឺ!!

ខៈ ហើយឥឡូវមិត្តឯងយកមួយណា២ហ្នឹង?ដូចខ្ញុំអត់
ដល់មិត្តឯងចិត្តធ្លុះដូចញ៉ុមអញ្ចឹងបានស្តាយកាំភ្លើងបាន
អត់ថាអត់ខ្លាចកាំភ្លើងផងមានអីអត់ហ៊ានដែរ
គេថាអោយញ៉ុមម៉េចហ៊ានថាអញ្ចឹង?ហ្ហំងាប់ចោលទៅ!!

កៈ ដល់ពេលហ្នឹងវាដូចថាវាលែងខ្វល់អីហើយអ៊ំហោ?

ខៈ វាថារាល់ថ្ងៃមិត្តឯងទាំងអស់គ្នាអត់ដឹងទេហិ អត់ដឹងថាមិត្តឯងជាប់គុកទេ ជាប់គុកណា? អើយជាប់អាគុកអត់ជញ្ជាំងហ្នឹង ដើរទៅណារួច គេវាស់ដីអោយដីរាល់ថ្ងៃនេះ ។

កៈ ចាំ!!

ខៈ ហ្នឹងមិនដូចជាប់គុក។

កៈ ហ្នឹងហើយ!!

ខៈ  គេថាអោយញ៉ុមអញ្ចឹង។

កៈ ហ្នឹងហើយមែនគេវាស់ដីអោយដើរមែនហ្នឹងអ៊ំ!!

ខៈ វាស់ដីអោយដើរមែនតើ ហ៊ីអាណាសហាករណ៍ត្រឹមប៉ុន្មានត្រឹមប៉ុន្មានត្រឹមហ្នឹងហើយ !!កៈ ចាំ!!ខៈ ចេញផុតពីហ្នឹងរបស់គេគេយកបាញ់ចោលឥឡូវហ្នឹង!!

កៈ អ៊ំពេលហ្នឹងអត់មាននាំគ្នាគិតថាអត់មានរត់ចេញពីរបបចង្រៃយកហ្នឹងទេហោ?

ខៈ រត់អីបាន។

កៈ គ្រប់កន្លែងម៉ងហោ?

ខៈ  ដូចថាឃើញទេហោ គេថាគុកអត់ជញ្ជាំងហា!!

កៈ ចាំ!!

ខៈ មានជញ្ជាំងកន្លែងណា។

កៈ ចាំ!!

ខៈ នាក់ហ្នឹងគាត់ប្រធានគាត់រំដោះចាស់ដែរ
គាត់ថាញ៉ុមឆ្លាតម្លេះ!!ហើយសួរញ៉ុមអត់ចេះអក្សរលើង អត់ដែលចេះអក្សរ
មានដែលចេះអក្សរអីពេលបង្រៀនហាំ !!ថ្នាក់ទី៥ទីអីគេថាយើងនិស្សិតហាំ
គេល្បួងយើងអោយយកទៅបង្រៀនគេអាងគេល្បួងយើងយកទៅវៃចោល!!

ក៖ ចាំ!!

ខ៖ យកទៅវ៉ៃចោលទាំងអស់អាអ្នកចេះអក្សរហាំ!!ហើយដល់ហើយញ៉ុមថាអត់ចេះទេ !!

ក៖ ហើយអ៊ំពេលហ្នឹងមានដែលឃើញគេយកមនុស្សយកទៅសម្លាប់ចោលទេ?

ខ៖ មីអូនឯងចងទាំងខ្សែហ៎!!

ក៖ ឃើញម៉ងអ៊ំហោ?

ខ៖ ចងខ្សែអំបោះដាច់ហ៎បាញ់ចោលភ្លាម អោយកាន់ខ្សែអំបោះហ្នឹងហ៎
តែហ៊ានរើសដាច់បាញ់ចោលទីហ្នឹងអ្នកឯងមិនចាំបាច់ទៅដល់កន្លែងទេ!!

ក៖ ចំ!!

ខ៖ ងាប់តាមផ្លូវហើយ។

ក៖ ហើយអ៊ំកន្លែងដែលគេសម្លាប់ហ្នឹងនៅឆ្ងាយទេ?

ខ៖
អ្នកនៅស្វាយរៀងទៀតហ្ន៎!!ហ៊ីស្រេចគេគេធ្វើអាកន្លែងមន្ទីរអាកន្លែងសម្លាប់មនុស្សកន្លែងដាក់ទោស ប៉ុន្មានថ្ងៃហ្នឹង!!

ក៖ និយាយទៅគេប្រាប់ម៉ងហោ ថាបើសិនជាធ្វើខុសគេយកទៅសម្លាប់ចោលម៉ងអ៊ំហោ?

ខ៖ តែក្របីស៊ីស្រូវមួយគុម្ពក៏យកបាញ់ចោលដែរ គ្នាអ្នកឃ្វាលក្របីហាំ អ្នកឃ្វាលក្របីឃ្វាលគោហាំ!!ស៊ីរបស់គេតែមួយគុម្ពថាមិត្តឯងប្រហែស!!

ក៖ ហ្ន៎!!

ខ៖ អត់មានគោលជំហរច្បាស់លាស់!!

ក៖ ចាំ!អ៊ំមានដែលឃើញមនុស្សស្លាប់នៅកន្លែងធ្វើការ ដួលស្លាប់នៅថ្មោលទៅទេ?

ខ៖ ច្រើនណាស់អូន!!

កះ ឃើញឡើងសុំក្អែកហើយអ៎ហេ?

ខះ ឡើងទៅដេកកន្លែងខ្មោចលែងខ្លាចហើយហ្នឹង។កះ ហ៊ឺ!!ខះ បើញ៉ុមទៅស្រែប្រាំង ទៅស្រែប្រាំង អាមួយនោះរត់ពីសហាករណ៍គេមក មកពីលោតពីលើចុងត្នោតមកងាប់នៅក្នុងសហាករណ៍ខ្ញុំ។

កះ សម្លាប់ខ្លួនឯងម៉ង?

ខះ ហ្នឹងហើយ ស្អាតណាស់អាហ្នឹងបែបកូនចិន ។

កះ ចា៎!!

ខះ បងនារី ហៅញ៉ុមអញ្ចឹង សហាករណ៍ហ្នឹងស្លាប់អស់ហើយសហាករណ៍ក្បាលឈើពុកហ្នឹង!!ហ៊ឺបងនារីអើយ!!ហើយអូនឯងម៉េចបានហ៊ានឡើង?គេមកទាន់គេ!ហ៊ឺចុះក៏ស្លាប់នៅក៏ស្លាប់ដែរញ៉ុមសូមហូបទឹកត្នោតនេះ សិនវាថាសហាករណ៍ក្បាលឈើពុកអោយគេធ្វើរឆ្អឹងផង។

កះ លោតធ្លាក់!

ខះ  លោតមកម៉ង!!ឆ្លបគេមកហៅកាន់កាំភ្លើងនៅក្រោមដើមហ្នឹង។កះ ហ៊ឺ!!ខះ ស្រាប់តែវាអត់ចុះវាលោត វាថាចុះក៏ស្លាប់ ចុះស្លាប់ទាំងវេទនាបើលោតព្រឹបមកងាប់ម៉ង!!!

កះ ងាប់ហើយលោកអើយលោក!!

ខះ អានិតណាស់លោកអើយ!!

កះ អ៊ំញ៉ុម!

ខះ ហើាយផ្លូវហ្នឹង ផ្លូវហ្នឹងឯងដើរកាត់មកយករបបអោយ អោយ!!

កះ ហើយធ្លាក់មកបាក់ករងាប់បាត់ទៅ?

ខះ ហ៊ឺធ្លាក់មកបោកក្បាល។

កះ ខ្ពស់ទេអ៊ំ?

ខ៖ ត្នោតខ្ពស់ហាំ គ្រាន់តែងើយអញ្ចេះ ឡើងទៅស្លូតមុខស្លូតក្បាលហាំ!!

ក៖ ហ៊ឺ!! ហើយពេលហ្នឹងមានបង្អោងមានអីឡើងធម្មតាអញ្ចឹងទៅ?

ខ៖ បង្អោងគេដាក់ពាក់កណ្ដាលដើមហ្នឹង!!

ក៖ ហើយឡើងតទៅទៀតទៅ?

ខ៖ ហ្នឹងហើយ!!!វាថាដូចថាល្បាប់២ម៉ែត្រអីហ្នឹងឡើងដល់
បង្អោងអារៀងខ្លីៗអាត្នោតគេរៀងទេអញ្ចេក !!

ក៖ ចាំ!!

ខ៖ តែវាដល់លើវាត្រង់ហាំ!!

ក៖ ហ៊ឺៗ!!អូយអ៊ំអើយអ៊ំ!គ្រាន់តែឮពេលអាពេលហ្នឹងក៏សាហាវម្លេះអ៊ំអើយ!!

ខ៖ ក្មេងឥឡូវគេអត់ជឿទេអូនណាស់!!វាអត់ដែលទៅឆ្លងកាត់!!

ក៖ ហ្ហំញ៉ុមជឿ ញ៉ុមជឿ! អ៊ំដឹងម៉េចទេ
អាយប់ថ្ងៃមុនញ៉ុមភ្ញាក់មកញ៉ុមមើលអានៅក្នុងទូរសព្ទ័ហ្ហំ!!ចូលអាក្នុងទូរទស្សន៍អាវាមានហ្វេសប៊ុកមានអីហ្ហំ!!

ខ៖ ហ៊ឺ!!

ក៖ គេបង្ហោះអារូបជំនាន់ហ្នឹងហ្ហំ!!អារឿងអាប្រិនគេនោះអ៊ំ អ៊ំឯងស្គាល់ទេ?

ខ៖ អាហ្នឹងអត់ទេ!

ក៖ អាហ្នឹងពីរបបប៉ុល ពតដែរតើអ៊ំ!

ខ៖ ចាំ!!

ក៖ ដឹងម៉េចទេអ៊ំវាចាក់ វាដូចរបៀបថា ញ៉ុមអត់ដឹងថាគេថតអាម៉េចបានទេ!!

ខ៖ ចាំ!!

ក៖
សាកសពហ្នឹងអ៊ំមិននៅក្នុងរណ្ដៅហ្នឹងអ៊ំហើយមានទឹកភក់បក្សៗពេលនៅកណ្ដាលវាលស្រែអី
ហ្នឹងថារៀបថាវាលសុទ្ធតែឆ្អឹងខ្មោចអាខ្លះទឹមតែងាប់
អាខ្លះងាប់ហើយរលេសរលួយអីវ៉ាន់ហ្នឹងអ៊ំអើយថាវាថាញ៉ុមឃើញញ៉ុមថាញ៉ុមគួរអោយខ្ពើម
ថាអើយមានអារម្មណ៍ថាខ្លាចខ្លាំងហា៎!!

ខ៖
ហ៊ីអូនណ្ហើយពេលញ៉ុមដើរកាត់ហា៎ម៉ោងមួយបើវាអស់ស្បៀងហា៎គេត្រូវអោយយើងឡើងមក
យកស្បៀង!

ក៖ ហ៊ី!!

ខ៖ បររទេះគោ អូយកុំរៃញ៉ុមញ៉ុមអត់ដឹងអីទេ។

ក៖ ហ៊ីស្រែកហៅអញ្ជឹងម៉ងអ៊ំហេ?

ខ៖ ស្រែកម៉ែអើយជួយកូនផង សម្លាប់ហ្អែងអ្នកណាទៅកំនត់
រៃចោលរៃចោលហ្អែងហើយមន្ទីរគេធ្វើវែងណាស់អូនណ្ហើយកន្លែងសារៈមន្ទីរដាក់អ្នកទោស
គេដាក់អញ្ជឹង អោយនៅកណ្ដាលវាលស្រែល្ហល្ហេវ!!!

ក៖ ញ៉ុមឡើងស្ដាប់អ៊ំនិយាយថាដូចថារៀងខ្សេវម៉ងហា៎!!

ខ៖ ញ៉ុមក៏ថាញ៉ុមអត់រស់ដែរ
តែញ៉ុមទៅ៣ឆ្នាំ៨ខែ២០ថ្ងៃហ្នឹងហា៎កូនណាស់!!គ្មានអ្នកណាកសាងខ្ញុំបាន!!

ក៖ បានម្ដងទេហេ?

ខ៖ តែមួយចុងម៉ាត់មួយកំណាត់ម៉ាត់ក៏អត់មានផង!!

ក៖ អ៊ំពេលហ្នឹងបានធ្វើល្អរហូត ពេលហ្នឹងគេស្រលាញ់អ៊ំរហូតម៉ងអ៊ំហេ?

ខ៖  ខ្ញុំមិនដែលទៅនេះធ្វើអីទេ តែមុនដំបូងញ៉ុមនឹកអានិតតែប៉ាក្មេកញ៉ុម
គេអោយគាត់ចូលរោងសិប្បកម្មបិតធ្វើក្រឡោះគោវិញខ្សែគោហើយគាត់ថាហ៊ីបានកូនប្រសារ

មួយចំណាប់ទៅអ្នតៗប្រាប់តាតាដូចគ្នាហ្នឹងហាំ!!ហ៊ីលីតែឪពុកក្មេកអ្នតថាចំណាប់ណាស់ខ្មៅតែរូបរាង តែធ្វើការស្អាតដឹងម្ដាយឪពុកណាស់។

កះ ចាំអញ្ចឹងអំពេលនៅក្នុង នៅក្នុងជំនាន់ប៉ុល ពតហ្នឹងតែដាំបាយតែមួយមុខហ្នឹងទេហី?

ខះ  ញ៉ុមហេ

?កះ ចាំ!!

ខះ ញ៉ុមគេអោយទៅជីកប្រឡាយបានមួយថ្ងៃជំនួសគេមួយថ្ងៃពីរថ្ងៃគេឈឺ!!

កះ ចាំ!!

ខះ កូនគេឈឺនោះញ៉ុមទៅជីកបានពីរថ្ងៃហ្នឹងដែរ។

កះ អញ្ចឹងពេលឈឺគេអោយសំរាកដែរ?

ខះ ឈឺគេអោយយើងចូលពេទ្យ។

កះ  ពេទ្យគេហ្នឹងគ្មានស្អីណាទេហី?

ខះ មានតែថ្នាំអាចមន៍ទន្សាយហ្នឹងមានថ្នាំសរមកពីណា។

កះ ហើយមានសារ៉ូមអីគេគេដែរអំហេ?

ខះ  ដូចមានសារ៉ូមដែរហេ សារ៉ូមហ្នឹងទាល់តែកម្មាភិបាលគេបានបានដាក់ យើងដេកទៅ។

កះ យកមកពីណាវិញអំអាសារ៉ូមហ្នឹង យកមកពីស្រុកគេដែរអំហី?

ខះ  ហ៊ីពេលយកនៅក្នុងភ្នំពេញ ពេលបែកទៅគេបារយកទៅ!!!

កះ ហ្ហ៎!!តាមពិតពេលហ្នឹងហាំ!!

ខះ តែស្រុកហ្នឹងវាអាពតវាមិនស្គាល់ថ្នាំដុះធ្មេញផងហ្នឹង វាយកថ្នាំដុសធ្មេញទៅស៊ីហ្នឹង!!

កះ ហ៊ីសឆ្កួតសុទ្ធអាឡប់ ឡប់ម៉ងអាឡប់។

ខ៖  អោយតែយើងរាងក្រអូបតិចថា ហ៊ីអត់ចោលអាក្លិនចក្រពត្រ័ នៅក្រាស់ញ៉ុក
មិនទាន់ខាត់អោយអស់ទេ!!ក៖ ហ៊ឺ!!ខ៖
តាមការពិតវាដឹងឪពុកក្មេកញ៉ុមមុនស្លាប់បានកូនញ៉ុមអាបងមួយហ្នឹងហា៎
ទឹកអប់អាតាប៊ុយហ្ន៎!!ក៖ ចា៎!!ខ៖ អាដប៩ជ្រុងហា៎គាត់ទុកអោយហា៎ !!

ក៖ ហ៊ឺ!

ខ៖ ដល់នេះទៅពេលកូនឯងឆ្លងទន្លេបានទឹកអប់ហ្នឹងហើយ
យើងមកស្រុកនេះគ្នាសាប៊ូគ្មានអីទេ!!

ក៖ ហ៊ឺ!!!

ខ៖ អីចឹងទៅវាដើរកាត់ផ្ទះយប់!!

ក៖ ឈ្មុយអ៊ំហេ?

ខ៖ យកត្រីងៀតយកអីមកដូរហា៎!!ក៖ ហ្ន៎!!ខ៖ ដល់ហើយយកថ្នាំពេទ្យថ្នាំយើង !!

ក៖ វាចង់បានអាក្រអូបហ្នឹងហេ?

ខ៖  យកមកអោយ បងនារី!!

ក៖ លែងហៅអាចក្រពត្រ័ទៀតហើយហេ?

ខ៖  ចង់ស្អាតជាងយើង មីស្រីៗហ្ន៎!!

ក៖ ចា៎ហ្នឹងហើយអ៊ំដល់ពេល ម៉េចអ៊ំ?

ខ៖  តែបើប្រធានពេទ្យឈ្មោះលឹម លឹមហ្នឹង មែនគាកត់អត់ចង់បានរបស់គេទេ
គាត់ចេះមានធម៌ចំពោះយើងហា៎!!

ក៖ ចា៎!!

ខ៖  គាត់ក៏ទំងន់ដែរ ប្តីគេកាន់កងប៉ុន្មានរយ ៥០០កងហ្ន៎ មកកន្លែងហ្នឹងញ៉ូមភ័យដែរហ្នឹងហា៎
ឆ្លបទៅហៅ អោយតែឆ្លបទៅហៅអត់រស់ទេណាស់!!

កៈ ហ៊ឺៗ!!

ខៈ តែឆ្លបហៅយកដឹងតែបាត់ខ្លួនហើយ។

កៈ ចាំ!!

ខៈ ហើយអ្នកជំងឺគេថា អុញមិត្តនារីហ្នឹងបងនារីហ្នឹងថីពោះធំផងគេហៅទៅទៀត
គេហៅអោយយើងទៅហូបបាយ ក្នុងមន្ទីរមែនតែគេធ្វើផ្ទះអោយប្រពន្ធគេផ្សេងហាំ!!

កៈ ចាំ!!

ខៈ អត់មាននៅជាមួយពេទ្យច្របូកច្របល់ទេ
ហ្នឹងបែបមកឃើញប្រពន្ធកាត់សក់ស្អាតហាំអោយញ៉ុមកាត់អោយនោះ អ្នកគេអ្នកកាត់
ហ៊ឺអ្នកជំងឺមួយពោះធំដែរគាត់មានផ្ទៃពោះដូចញ៉ុមដែរគាត់កាត់អោយ !!
អ្នកណាដេរម្ជូកអោយ?មិត្តនារីហ្នឹង!!

កៈ ហ៊ឺ!!

ខៈ ហើយគេអោយឆ្លបទៅហៅញ៉ុម ញ៉ុមភ័យណាស់!!

កៈ  ភ័យចង់ងាប!!

ខៈ ហ្នឹងនៅមន្ទីរពេទ្យផង តែហៅងាប់ហើយក្នុងកងយើងក៏ដោយ។

កៈ ចាំ!ហើយហៅអោយហូបបាយហើយអោយមកវិញមក!!

ខៈ ទៅហ្នឹងហើយ ហើយទៅទៅឡើងទៅ ម៉ែអើយគេកំពុងតែស្ងោរមាន់ឡើងឈ្ងុយ!!កៈ
ហ៊ឺ!!ខៈ ហើយអាឆ្នាំងក្រាស់ៗគេនោះ។

កៈ ចាំ!!

ខៈ ប៉ុនៗនេះច្រឡឹងៗគេដាំបាយ ភ័យទេ សួរញ៉ុម ភ័យទេមិត្តនារី ញ៉ុមភ័យដែរបង
ហ៊ឺហៅមកអោយ បងមិត្តនារីញ៉ុមថាចេះកាត់សក់ ចេះដេរម្ជូកស្អាតៗណាស់!!

កៈ ចាំ!

ខ៖ អញ្ចឹងហូបបាយ ហូបអោយឆ្អែតទៅ។

ក៖ ហ៊ីពេលហ្នឹងប្រធានឆ្លបហេ ហាប្រធានពេទ្យហេ?

ខ៖  គាត់ គាត់ប្រពន្ធគេប្រធានពេទ្យ។

ក៖ ចាំ!

ខ៖ កាន់កាប់មួយពេទ្យហ្នឹងតែម្ដង!!

ក៖ ចាំ!!!

ខ៖ ហើយប្ដីគេកាន់កងរយចេញសមរភូមិ។

ក៖  ហើយអ៊ំពេលធជំនាន់អាពតហ្នឹងមានអ្នកខ្លះគេចិត្តល្អដែរ ។

ខ៖ ចាំ!!

ក៖ តែអ្នកខ្លះក៏ចិត្តសាហាវ សាហាវខ្លាំងមែនទែនម៉ង?

ខ៖  ហ៊ីហើយមើលទៅគាត់មិនសមអ្នករំដោះចាស់ទេ ចរិកហាំ!!

ក៖ ចាំ!!

ខ៖ ញ៉ុមមើលទៅមិនមែនដូចចរិកអ្នករំដោះចាស់ទេ។

ក៖ ហ៊ីៗ!

ខ៖ ដូចថាគាត់រាងទន់ ភ្លន់គាត់ដូចជារាងមិងកោងកាច ឃើញយើងហូបបបរ ពេលញ៉ូមពេលគេចែកបបរញ៉ុមរត់ហើយ ញ៉ុមឃើញបបរញ៉ុមក្អួតម៉ងអោយខ្ពើម។

ក៖  ពេលមុនមានកូនហេ?

ខ៖  ហ្នឹងហើយពេលញ៉ុមមទម្ងន់ញ៉ុមកូនបងគេនោះ។

ក៖ ចាំ!

ខ៖ ហើយគាត់យកអង្ករមកអោយមួយកំប៉ុងទុកដាំ។

ក៖ ហេងហើយអ៊ំបានគេចេះស្រលាញ់ច្រើនពេលទម្ងន់។

ខ៖  បានញ៉ុមថាពេលមុនញ៉ុមនៅជាមួយគេញ៉ុមដាក់បាត្រលោកហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ អ៊ីចឹងកុសល្យហ្នឹងបានជះអោយញ៉ុម។

ក៖ ហ្នឹងហើយ!!ចាំ!!

ខ៖ ញ៉ុមដឹងអញ្ចឹងម៉ង!!

ក៖ ចាំ អញ្ចឹងអ៊ំពេលបែកជំនាន់ប៉ុល
ពតមកអ៊ំដូចអ៊ំនិយយាអ៊ីចឹងអ៊ំក៏បានកាប់ជ្រូកហេអ៊ំលក់ជ្រូក អ៊ំអោយជ្រូកថៅជ្រូកហ្នឹងហេ!!

ខ៖ ប្តីញ៉ុមចេះបានជ្រូកហ្នឹង។

ក៖ ហ៊ីអានិតគ្នាទៀតហ្នឹងណាស់អ៊ំ
ចេះបានចិញ្ចឹមបានចិញ្ចឹមរស់បានយកលុយមកស្រុកវិញ។

ក៖ ញ៉ុមខំថាអញ្ចេកហ្ហ៎ឪអើយ យើងមក៣ឆ្នាំ៨ខែ
២០ថ្ងៃគេចង់រស់ដូចយើងដែរថ្ងៃក្រោយអូនឯងកុំទៅសម្លាប់ជីវិតគេហាប្រាប់ប្តីមិនទាន់បានប៉ុន្មាន ហ៊ីបងទៅជាមួយគេហើយណាស់ ស្រាប់តែងើបតាំងពីយប់ទៅ
អត់មានហៅញ៉ុមអីមួយម៉ាត់។

ក៖ ហើយឮដំណឹងថាស្លាប់ទៅ?

ខ៖ ទៅគេបាញ់ជ្រមុជទឹក។

ក៖ ហ៊ី!!

ខ៖ ទៅយកបានតែខោអាវបានមកហ្នឹង អ្នកទៅជាមួយគេមកប្រាប់
ញ៉ុមចេះតែបាត់ប្តីញ៉ុម៧យប់ហើយអត់ឃើញមកហ្ហ៎ហើយកូនទឹមតែចេះវាចេះអង្គុយហ្នឹង។ក៖

ចាំ!!ខ៖ ញ៉ុមអានិត ដល់នេះទៅប្អូនៗយំឡើងមួយទំហឹង ហ៊ីនៅសល់តែបងមួយហ្នឹងផង!!ក៖ ចាំ!!ខ៖ ឥឡូវបងស្លាប់។

ក៖ ចាំ អាជិតមកហើយហ្នឹងហាំ!!

ខ៖ មកហើយហ្នឹងមកនៅពោធិ៍សាត់ហើយហ្នឹង!!ក៖ អើយ!!ខ៖ ជិតមកស្រុកហើយ។

ក៖ ទៅអីចឹងទៅ នៅសល់តិចតួច ពួកអាត្រូវគ្រឿងអស់ហ្នឹង !!!

ខ៖ ហើាយយើងចូលពោធិ៍សាត់បានតែប៉ុន្មានហ្នឹងប៉ុន្មានឆ្នាំខ្មែរហ្នឹង!!ក៖ ចាំ!!ខ៖ ចូលឆ្នាំខ្មែរហើយញ៉ុមនិយាយទៅវៀតណាមចេះខ្មែរខ្លះៗនោះវាចេះ វាចេះចង់បានអាថ្នាំខ្លាំងនោះ។ក៖ ចាំ!!ខ៖ ហើយប្ដីញ៉ុមគាត់ចូលចិត្តទៅរកអាថ្នាំខ្លាំងហ្នឹងយកមកហាន់ទុកហ្នំ!!មកអោយមួយឆ្នាប់ទៅហ្នំ !! អោយថ្នាំពេទ្យយើងសុទ្ធតែអាល្អៗ!!ក៖ ហ៊ឺ!!ខ៖ ហើយអោយចេះបង្រៀនពួកអយើងអោយនិយាយ ហៅផ្តិលទឹកហៅអី ពេលមុនញ៉ុមច្រើនណាស់!!

ក៖ វៀតណាមហោ?

ខ៖ វៀតណាមហាំ ញ៉ុមមកនៅពោធិ៍សាត់ហ្នឹង គេថាអត់ វៀតណាមចិត្តអាក្រក់ម៉េចវៀតណាមនេះចិត្តល្អ!!

ក៖ ទៅតាមមនុស្សទេអ៊ំអើយ!!

ខ៖ ហើយមកប្រាប់យើងអោយធ្វើ!!

ក៖ ចាំភាគច្រើនដោយសារប្រវត្តិខ្មែរយើងហើយនឹងវៀតណាមហ្នឹង វាជូរចត់ច្រើនពេក។

ខ៖ ហ្នឹងហើយ !!

ក៖ ចាំអញ្ចឹងអ៊ំបន្ទាប់ពេលបែកជំនាន់ប៉ុល ពតមកអ៊ំរកស៊ីអីគេដែរ?

ខ៖ ញ៉ុមបែកពីស្រុកមកញ៉ុមមកធ្វើស្រែហ្នឹងម៉ង!!

ក៖ ធ្វើស្រែចំការហ្នឹងម៉ង?

ខ៖  ហ្នឹងហើយ។

ក៖ ហើយដល់ពេលឥឡូវអស់ស្រែអត់មានអីធ្វើទៀតទេអ៊ំហោ?

ខ៖ ហ្នឹង !!ហ្នឹងហើយ!!

ក៖ ដោយសារម៉េចបានលក់?

ខ៖ តែផ្ទះក៏អត់មាននៅផងមកនៅជាមួយកូន!!

ក៖ ដោយសារឈឺអញ្ចឹទៅអ៊ំហោ លក់អស់អញ្ចឹងទៅអ៊ំហោ?

ខ៖  ហ្នឹងហើយ ហ្នឹងហើយ
អាដីហ្នឹងគេអោយក្បាលដី១០ម៉ែត្រគេលក់អាក្បាលដីលើមេភូមិហ្នឹងគេចែកអត់ចេញគេដេញយើងអោយមកនៅនេះ គេថាលក់ទៅចាំគេមានកន្លែតងអោយនៅអ្នកនៅប៉ុន្មានគ្រួសារហ្នឹង!!

ក៖ ចាំ!!

ខ៖ ៧គ្រួសារហាំកាលដំបូងហាំ!!

ក៖ ហុី!!

ខ៖ ទឹមតែមកពេញច្រើនដោយសារដីនោះ!!

ក៖ អញ្ចឹងអ៊ំពេលមុនដីហ្នឹងដីប្រឡាយទេណោះ?

ខ៖  ដីប្រឡាយតើ!!

ក៖  គេ គេចាក់បំពេញ គេចាក់បំពេញតើហី?ខាងក្រោមមានទឹកទេ?

ខ៖  ទឹកហ្នឹងទឹកប្រឡាយតាំងពីជំនាន់ញ៉ូមកើតណោះឃើញម៉ង!

ក៖ ចាំ!!

ខ៖ គេហៅអូរតាសាយហ្នឹងហ្នំ!!

ក៖ ឥឡូវជិតអស់ហើយហោ?

ខ៖  ឥឡូវជិតអស់ហើយ មើលកូនញុំមចាក់ដីអស់ច្រើនណាស់បានបានដីខ្ពស់អញ្ចឹងហា!!

ក៖ ចាំ!!

ខ៖  នោះ នោះអាដីអត់ចាក់នោះ អាដីផ្ទះខាងហ្នឹង ។

ក៖ ហ្ហ៎!!

ខ៖ អត់ចាក់ដីផ្ទះកំពស់ប៉ុណ្ណឹងហ្ហ៎!!ទឹកហូរសំរាប់ ដូច ដូចថាស្រូវធ្ងន់ហាំ!!

ក៖ ចាំ!!!

ខ៖  ពេលគេច្រូតមកគេបង្ហូរចូលបឹកកក់មកវារីងស្រួលច្រូត!!

ក៖ ចាំ!!

ខ៖ ចាស់ពីដើម!!

ក៖ ហ៊ីៗ!!

ខ៖ ហ្នឹងប្រឡាយហ្នឹង ប្រឡាយពីដូនតាមកទេ តែកន្លែងហ្នឹងក៏តំរូវរដ្ឋដែរអូនអើយ!!

ក៖ ចាំ!!អញ្ចឹងអ៊ំប្លង់រឹងមានទេអ៊ំនេះ?

ខ៖  អត់ទេ
កូនញុំមថាម៉ែអើយបើគេចង់បានប៉ុណ្ណាគេយកប៉ុណ្ណឹងទៅ!!ម៉ែឯងមិនបាច់ភ័យទេយើងនៅប៉ុណ្ណាក៏យើងនៅបានដែរ!!

ក៖ ចាំ អើយតែនេះគេយល់ប្រជាជនហើយអ៊ំ ចាំ!!

ខ៖ ហើយអ្នកខ្លះអ្នកភ្នំពេញផ្លូញអត់ ញុំមថា ហ៊ីផ្ទះហ្នឹងធ្វើគេអោយលុយខ្ចីទេ។

ក៖ ចាំ!!

ខ៖ គ្មានលុយពីណាយកមកសងគេរួចទេ!!

ក៖ ហ៊ឺ!!

ខ៖ តែគ្រាន់តែថាវាម៉ែក្មេកគ្រាន់ បើគាត់នឹកឃើញទៅគាត់មិនទាស់យើងក៏ម្យ៉ាងដែរ!!

ក៖ ចាំ!

ខ៖ យើងតស៊ូជាមួយគាត់គាត់ក៏ឃើញដែរ។

ក៖ ហ្នឹងហើយ គាត់មិនទៅទារអីគាត់ទេ គាត់ចាស់គាត់មានលុយអីវ៉ាន់ណោះហ្ន៎!!

ខ៖ ហើយគាត់ទឹកនោមផ្អែមហាំ គាត់កូនចៅក្មួយគេចេះតែយកទៅថៃអីចឹងទៅ អាមេរិចអញ្ចឹងទៅដើរអស់ហើយ គាត់ដើរ គាត់ដើរលេងអោយសប្បាយហាំ!!

ក៖ ហ្ន៎!!អីចឹងទៀតល្អអញ្ចឹងទៀត!! អីចឹងអ៊ំមួយនេះសំនួរមួយចុងក្រោយ ចុងក្រោយហើយ អីចឹងអ៊ំមានពាក្យពេចន៍អីគេខ្លះចង់ផ្តែផ្តាំទៅកាន់កូនខ្មែរជំនាន់ក្រោយក៏ដូចជាកូនចៅរបស់អ៊ំហ្នឹងអោយគាត់ដើរលើផ្លូវម៉េចដែរអ៊ំហា?

ខ៖  ចង់អោយកូនចៅជំនាន់ក្រោយកូនញ៉ុមក្តីកូនគេក្តីអោយដើរតាមផ្លូវល្អអំពើសុចរិត។

ក៖ ចាំ!!

ខ៖ កុំគេញប្រវ៉ាញ់។

ក៖ ហ្នឹងហើយអ៊ំត្រូវហើយ!!

ខ៖ អញ្ចឹងរាល់ រាល់អាអំពើរល្អរបស់យើងអ្នកធ្វើអំពើរអាក្រកក់វាអត់ឈ្នះអំពើល្អទេ!!

ក៖ ចាំត្រូវហើយអ៊ំ។

ខ៖ គ្រាន់តែមុនហើយនឹងក្រោយហ្នឹង!!

ក៖ ហ្នឹងហើយ!!

ខ៖ ហ្នឹងហើយ ញ៉ុមចង់ផ្តាំផ្ញើរបានតែប៉ុណ្ណឹង។

ក៖ ចាំហ្នឹងហើយ!!

ខ៖ ហើយអោយតស៊ូឡើង យើងដួលខ្លួនយើងយើងងើបខ្លួនយើងកុំអោយគេលើកហាំ!!

កៈ ចាំចាំ!!

ខៈ ដូចអ៊ំអញ្ចឹងហា!!អ៊ំអត់អោយអ្នកណាគេលើកផង
តែកូនរបស់អ៊ំអ៊ំអត់អោយលើកផង!!ញ៉ុមងើបខ្លួនឯង!!

កៈ អ៊ំសុខចិត្តធ្វើគ្រប់មធ្យោបាយដើម្បីចិញ្ចឹមជីវិតអ៊ំណោះ?

ខៈ ចាំ!!

កៈ ចាំហ្នឹងហើយ។

ខៈ ហ្នឹងហើយ។

កៈ ចាំអរគុណអ៊ំច្រើនខ្លាំងមែនទែនសំរាប់ការសំភាសន៍ដ៏ក្បោះក្បាយអំពីជីវិតរបស់អ៊ំ
វាច្រើនខ្លាំងមែនទែន
ហើយជូនពរអោយសុខសប្បាយសុភមង្គលសុខភាពល្អតទៅមុខទៀតអ៊ំណាស់ចាំ!!

ខៈ ដូចគ្នាណាស់កូនណាស់!!!

កៈ ចាំសុខសប្បាយណាស់អ៊ំ។

ខៈ គាត់ធ្វើដំនើរទៅណាមកណាមានសមត្ថភាពទាំងទៅទាំងមក។

កៈ ចាំអរគុណ។

ខៈ សូមអោយទេវតាឆ្នាំថ្មីតាមថែរក្សាគ្រងមុខកូនកុំអោយមានជំងឺឈឺថ្កាត់អីទាំងអស់។

កៈ ចាំ អរគុណណាស់អ៊ំ!!

ខៈ  ចាំចាំ។។